នាងចង្អុលទៅខាងក្រៅបង្អួចដែលលោកឱត សាម៉ុនងាកទៅ ឃើញ ឯកមានដើរចូលមក ប្រញិបប្រញាប់។

គាត់ដឹងថាបុរសស័ក្តិបួននេះមានអ្វីមួយជំនួយដល់ការងារគាត់មិនខាន។

«ឲ្យគេតាមឲ្យកិតការពារកូនគ្រប់ជំហាន! តែរឿងអ្វីសំខាន់មិនបាច់ប្រាប់គេទេ ប្រាប់ប៉ាសិន! ប៉ាចាត់ចែង!»

«ចាំ!»

គាត់ធ្វើសញ្ញាឲ្យនាងចេញទៅ។ អមរាជាចាកចេញពីឪពុកទាំងកាយវិការនៅមិនជ្រះស្រលះ ដូច្នេះគាត់ផ្តាំតាមក្រោយ៖

«កុំភ័យ! ប៉ានឹងចាត់ការឲ្យគ្រប់យ៉ាងរៀបរយ!»

នាងហាក់មានទំនុកចិត្ត ប្រឹងបង្កើនភាពរឹងមាំជាងមុន ហើយឱបកុំព្យូទ័រចាកចេញទៅ។

ឯកមាននិងចិត្រា ចូលមកវិញយ៉ាងប្រញាប់...

«ខ្ញុំដឹងថាឯកមាន រកឃើញតម្រុយសំខាន់!»

គាត់និយាយស្វាគមន៍ស័ក្តិបួនទាំងទ្វេ។

បានដូចចិត្ត Hacker និយាយដំណាលពេលអង្គុយចុះកៅអីគាត់៖

«ជម្រាបប្រសាសន៍ទាន មហាវីនអាចថាកំពុងដឹងខ្លួនហើយ! ពេលយើងតាមដានវា វាប្រកាសរក Hacker ក្នុងផ្សារ បានន័យថា វាក៏កំពុងភ័យ!»

គេបង្ហាញតឹកតាងលើកុំព្យូទ័រ ធ្វើឲ្យឧត្តមសេនីយ៍ក៏ដូចជាចិត្រាចំហមាត់ធ្លុង។ «ចុះវាតាមដានអ្នកណា?»

ចិត្រារបូតមាត់សួរ ចំណែកឯកមាន បានឱកាសឆ្លើយឌឺមិត្តវិញផ្ទួង៖

«យើងមិនមែនទេវតាដែលដឹងរឿងគ្រប់បែបយ៉ាងទេអ្ហា!»

ចិត្រាមិនចុះញ៉មគេបញ្ចេញយោបល់បន្ទាន់៖

«ស្រួលបំផុត! ឯងមិនទៅធ្វើ Hacker ចូលទៅនៅក្បែរវាទៅ?»

«វាមិនមែនរក Hacker កាលីបយើងទេ!»

ចិត្រានិងឧត្តមសេនីយ៍ សម្លឹងមុខគ្នា។ ចិត្តធ្លាប់តែ យល់ថាឯកមានជាកម្លាំងដ៏សំខាន់ ហើយពេលឮអ៊ីចឹងមកវិញមានតែស្រងាកចិត្តព្រោះកូនអុកធំខ្លួនឯងសារភាពពីការពិតដែលគួរឲ្យដាច់ផ្ងារ។

សម្រាប់ឯកមាន ចិត្រាគ្មានអ្វីត្រូវទប់មាត់ នាយស័ក្តិបួនសួរបក៖

«ចឹងមានអីសង្ឃឹម? អ្ហះ? បើ Hacker ខាងចោរខ្លាំងជាងខាងប៉ូលិសទៀត! ថាមិនបានពេលយើងកំពុងនិយាយគ្នានេះ គេស្តាប់ឮអស់បាត់ហើយ!»

ឱិត សាម៉ុនដែលនៅស្ងៀមពិចារណាថ្លឹងថ្លែង ពេលនេះវាដែកាត់ដោយនិយាយសម្រាលស្ថានការណ៍៖

«បច្ចេកវិទ្យាពូកែមែន! តែកុំសុបិនបង្អើលខ្លួនយើងថាវាជាអាទិទេព! វាមានវិសាលភាពធំមហាសាល តែវានៅតែចាំបាច់ត្រូវស្ថិតក្រោមការគ្រប់គ្រងនៃដែនកំណត់មួយហៅថាច្បាប់ដូច្នេះមិនមែនវាចេះតែអាចធ្វើគ្រប់យ៉ាងបានទេ! បើគេអាចលបស្តាប់យើងបាន ទីមួយយើងនិយាយតាមបណ្តាញ ពីរយើងមានឧបករណ៍ដែលគេបង្កប់ក្នុងទីតាំងរបស់យើង ទីបីគេមានអ្នកនៅក្បែរយើងជារនុក!»

ចិត្រា ដាក់ផ្ទង៖

«បើរកជនបង្កប់ស្រួលទេគឺវានេះ!»

គេចង្អុលទៅឯកមាន ធ្វើឲ្យនាយ Hacker បើកភ្នែកធំៗ។ ចិត្រាសើចក្អាកក្អាយ ហើយបង្អាប់បន្តរដឹក៖

«វាចង់បានលុយណាស់ គេជួលវាលើស៥០០លាន វាទៅខាងគេបណ្តោយទាន!»

ឱិត សាម៉ុនញញឹម សម្លឹងភាពត្រង់ធ្លូនៃយុវជនទាំងទ្វេ។ បានបន្តិចគាត់និយាយពន្យល់៖

«ផ្ទះនេះមានសុវត្ថិភាព! ឡានរបស់យើងមុនចេញចូលឆ្លងកាត់ប្រព័ន្ធពិនិត្យទាំងអស់! គ្មានអ្នកណាអាចបង្កប់អ្វីបានទេ!»

ទូរសព្ទឯកមានមានសំឡេងរោទ៍ បង្អាក់ការពិភាក្សារបស់ពួកគេ។ គេដឹងថាជាអ្នកណាបានជាឱនគំនាប់លោកឧត្តមសេនីយ៍ហើយសុំអនុញ្ញាត។

«សុំទទួលទូរសព្ទអ្នកផ្ទះទាន!»

មានតែ ចិត្រាទេដែលដឹងច្បាស់ថា ឯកមានមានស្ថានភាពគ្រួសារបែបណា។ ពេលមិត្តក្រោកទៅ គេផ្លាស់ទឹកមុខតាមព្រោះគេដឹងថា ឯកមាននឹងជួបបញ្ហាទៀត ដោយសារអ្នកដែលខលមកនោះមិនដែលមកជាមួយរឿងល្អទេ។

លោក ឱត សាម៉ុន ចេញទៅបន្ទប់ទឹក អ៊ីចឹងហើយបាន ឱកាស ពេលបកពីទូរសព្ទមកវិញ ឯកមានសារភាពប្រាប់មិត្តតិចៗ៖

«ម៉ែរត់ចោលស្រុកទៀតហើយ! គាត់ឲ្យអញផ្ញើលុយទៅ!»

ចិត្រាដកដង្ហើមធំ៖

«ពេលណាមីងឈប់ងប់ល្បែងទេ?»

ឯកមាន អង្គុយចុះលើកដៃច្បូតមុខហើយរអ៊ូ៖

«ចាំមានពេលជួបគាត់ ជួយសួរសំណួរហ្នឹងទៅគាត់ជំនួសអញផង!»

ចិត្រានៅស្ងៀម មិនមាត់ ឯកមានបញ្ចេញវិបត្តិបន្ថែម៖

«អ្ហែងជួយគិតអញមើល! មនុស្សដូចអញមានម៉ែរបៀបអ៊ីចឹង ថ្ងៃក្រោយបើអញមានសំណាងបានកូនស្រីអ្នកធំ ឬមួយអញឡើងសក្តិជាផ្កាយ អញមានអីមានមុខមាត់ឲ្យគេស្តាប់ ហៅអញលោកនាយ?»

ចិត្រាឃាត់អារម្មណ៍សៅហ្មង របស់មិត្តដោយវិធីដដែលរបស់គេ៖

«គាត់ត្រូវការប៉ុន្មាន?»

«អញមិនយកលុយអ្ហែងទៀតទេ អាត្រាជំពាក់លើកមុន មិនទាន់បានឲ្យផង!»

វគ្គ ល្បែងHackនិងល្បិចមនុស្ស

មហាវីនឈានចុះពីឡាន ដែលមានអ្នកបើកទ្វារនិងហែហម។

គេត្រលប់មកផ្ទះវិញ ប៉ុន្តែគ្មានទេអារម្មណ៍សម្រាក។ មួយចប់តាមផ្លូវ នាយអ្នកមានកប់ក្តោងតែងតែរំលឹកនៅក្នុង អារម្មណ៍ខ្លួនឯងជានិច្ចថា គេមិនអាចសម្រេចចិត្ត ស្រួលៗលើរឿងដែលកំពុងតែកើតឡើងទាំងអស់នេះឡើយ។

«មកដល់ហើយទាន!»

ដេវីដអោនមកខ្សឹបពេលមហាវីនឈានចូលដល់ក្នុងផ្ទះកាលណា។

ធម្មជាតិរបស់មហាវីនជាកូនអ្នកមានដែលមិនដែលព្រមទទួលពាក្យ«ឈប់»ឬពាក្យថា«ចាញ់»។

គេធ្វើមុខក្រអឺតងាកមើលដេវីដហើយបណ្តេញពួកអ្នកដង្ហែ៖

«មិនបាច់ចូលមកទេ!»

អង្គរក្សដកថយអស់ គេងាកមកសួរដេវីដសាជាថ្មី៖

«វាមកដល់យូរហើយ?»

«ចុះពីយន្តហោះភ្លាមខ្ញុំនាំមកភ្លាម!»

«មានអ្នកណាឃើញអត់?»

គេសួរទាំងបោះជំហានៗទឹបៗ ឡើងទៅកាន់ជាន់ខាងលើ។

«ស្ងាត់បំផុតទាន! គ្មានអ្នកណាដឹងថា គេមកដល់ផ្ទះនេះទេ!»

មហាវីនញញឹមហើយអន្ទះសាចង់ឃើញមនុស្សសម្ងាត់។

គេប្រុងប្រយ័ត្នជានិច្ចហើយមិនទុកចិត្តនរណាទាំងអស់ ទោះម្នាក់ណាក៏ដោយជិតស្និទ្ធនឹងគេយ៉ាងណាក៏ដោយ។

«យុនប្រាវីត នេះគឺថៅកែវីនរបស់ខ្ញុំ!»

សភាពមនុស្សសម្ងាត់ពិតជាគួរឱ្យភ្ញាក់ផ្អើល ជាមួយអាវធុនថោកនិងមួកមិនដោះរបស់គេដែលមានស្លាកសញ្ញាស្រាបៀរ ជាមួកប្រភេទចែកFree។

«គេនេះ?»

មហាវីនចង្អុលបុរសថៃដែលស្រមាមប៉ាកហើយមើលទៅគ្រីគ្រ សុខភាពមិនល្អស្គមស្គាំង។

ដេវីដងក់ក្បាលអោនលំទោនចំណែកមាហាវីនអង្គុយច្រងាងបង្ហាញទឹកមុខខ្ពស់ហួសមេឃ។

«កុំឱ្យយើងដឹងថាឯងយកពួកប៉ាហ៊ីមកលេងបោកយើង!»

បុរសថៃដែលញញឹមមិនខ្វល់នឹងភាសាអង់គ្លេសរឹងកំព្រឹសគ្មានមនោសញ្ចេតនារបស់មហាវីនលូកយកលេបថប់មកចុច។

«ប្រាប់ឈ្មោះធនាគារលោកមកចុះ!»

មហាវីនដៀងគិត  មុនពេលឆ្លើយផ្ទួង៖

«ដាវីន! ROS-DAVIN»

ដៃបុរសតោកយ៉ាកលោតចុះឡើងលើKey ក្រោមការតាមដានរបស់មហាវីនមិនហ៊ានដាក់ភ្នែក។ ទូរសព្ទគេលោតសារ គេអោនពិនិត្យហើយ ងើបមុខមកវិញយ៉ាងរហ័ស។

បុរសតោកយ៉ាកញញឹមបញ្ចេញធ្មេញលឿងឆ្អៅរបស់គេ។

«៣០០០ដុល្លារនេះ ជាជំងឺចិត្ត!»

មហាវីនមុនដំបូងខឹង តែគេចាប់ផ្តើមសើចក្អាកក្អាយ។

«ឯងលួចលុយខ្ញុំដោយវិធីណា? សាហាវ! ពេញចិត្ត!»

ជនកន្ទាត់ចូលទៅកៀកហើយ ក្រៀកស្មាបុរសដែលទើបតែជ្រៀតចូលបណ្តាញរបស់គេហើយទម្លាក់លុយផ្ទេរអស់៣ពាន់ដុល្លារត្រឹមប៉ុន្មានដង្ហើម។

តាមថាមហាវីនមិនអាចឱ្យរបូតសូម្បីតែមួយដុល្លារណាដែលគេមិនចង់បាត់បង់ តែទេវតាអំណាចថាមពលម្នាក់នេះពិតជាធ្វើឱ្យគេសប្បាយចិត្តហួសថ្លែង។

«ចេញទៅ!»

គេបណ្តេញនាយដេវីឌហើយនៅស្ងាត់ៗតែពីរនាក់ជនជាតិថៃ។

ប្រសិនអ្នកណាម្នាក់យល់ច្បាស់អំពីបច្ចេកទេសHackយកទិន្នន័យ គេនឹងជឿថា ការទៅនៅលើទឹក ជាមធ្យោបាយល្អមួយទាំងរក្សាការសម្ងាត់និងប្រភពទីតាំង។

មហាវីនអ្នកមានក្មេងធាត់កន្ទ្រលរបស់យើង ត្បិតតែ ធំធាត់ឡើងក្នុងជោគវាសនាមិនដែលលំបាកឆ្លងកាត់ការតស៊ូ តែនេះមិនមែនមានន័យថាគេមិនឆ្លាតវៃនោះឡើយ។

បើគេព្រមជឿតាម Rose តែម្ខាងហើយ សុខចិត្តអង្គុយឱបដៃរង់ចាំនាងស៊ើបពី Lorenzo គេម៉េចនឹងសមជាថៅកែកាន់ប្រាក់រយលាន?

«លោកជួលខ្ញុំថ្លៃយ៉ាងនេះ ឲ្យខ្ញុំតាមដានតារាសម្បុរសម្នាក់ហ្នឹង???»

ភាសាអង់គ្លេសរបស់ជនជាតិថៃម្នាក់នេះពិបាកស្ដាប់ ព្រោះគេនិយាយអង់គ្លេសមិនសូវល្អទេ តែមហាវីនកោតស្ញប់ស្ញែងស្នាដៃផ្សេងរបស់គេ នោះគេគឺរហស្សនាមកំពូលអ្នក Hack លើផ្សារងងឹត។

អ្នកមានខ្មែរ តបតជាមួយគូសន្ទនា ដោយភាសាអង់គ្លេសដ៏ជំនាញរបស់គេ៖

«ខ្ញុំចង់ដឹងថា គេចាប់ស្រីៗអស់នោះដែរអត់យុន ប្រាវីត? ហើយមួយទៀត! ខ្ញុំចង់ឲ្យការងារនេះ ប្រព្រឹត្តិទៅស្ងាត់បំផុត!»

ជនជាតិថៃញញឹម សម្លឹងដុំប្រាក់សុទ្ធ ដែលត្រូវបានហុចមកពីមុខខ្លួន។ ចរាចរណ៍ប្រាក់សុទ្ធដ៏ងាយស្រួលក្នុងប្រទេសកម្ពុជា ជាពិសេសលុយដុល្លារអាមេរិក ធ្វើឲ្យអ្នករកស៊ីក្រៅច្បាប់ទាំងឡាយស្រក់ទឹកមាត់។

គេនិយាយព្រមពេលដៃឈោងមកទទួលលុយរង្វាន់៖

«កុំភ័យ គោលដៅការងារខ្ញុំគឺលាក់ការណ៍!»

គេនិយាយកុហកខ្លួនឯងតែប៉ុណ្ណោះ ព្រោះគេគួរតែដឹងហើយថានៅក្នុងសង្គម Hacker គ្មានអ្វីដែលហៅថាលាក់ការណ៍នោះឡើយ។

……………………………

នៅខាង Lorenzo ឯណេះវិញ គេកំពុងអង្គុយនឹងថ្កល់ ស្ដាប់អ្នកក្រោមឱវាទរាយការណ៍៖

«អ្នកជ្រៀតចូលកម្មវិធីការពាររបស់យើងឈ្មោះ Pravit មកពីភាគខាងត្បូងថៃកាន់សាសនាឥស្លាមធ្លាប់ទៅរៀននៅអាល្លឺម៉ង់! វានោះធ្លាប់មានប្រវត្តិខ្លាំងមិនធម្មតាដែរ ប៉ុន្តែមិនដឹងហេតុអីពេលនេះភ្លាត់ឲ្យយើងចាប់បានសញ្ញា!»

វាជាសម្ដីបរទេសច្រមុះស្រួចដែលកំពុងធ្វើការការពារបណ្ដាញឲ្យគេ។ បុរសនោះរៀបរាប់ច្រើនទៅតាមទម្លាប់អ្នកបម្រើ ប្រភេទដែលយល់ថា បើមានអ្វីរាយការណ៍ច្រើនកាន់តែល្អ។

Lorenzoនិយាយឡើងដោយទឹកមុខគ្មានប្រែប្រួល៖

«កុំបូរបាច់ច្រើន! ខ្ញុំចង់ដឹងអ្នកដែលនៅពីក្រោយគេ!»

«មហាវីន!»

ម្នាក់នោះឆ្លើយរហ័សណាស់ តែមិនប្តូរលឿនជាងទឹកមុខរបស់ Lorenzoទេ គេងើយមកសម្លឹង Roseជាមួយភាពទោមនស្សពេញប្រៀបក្នុងពន្លឺភ្នែក។

Rose ហាមាត់ប្រុងនិយាយអ្វីម្យ៉ាង ប៉ុន្តែនាងបង្អង់វិញ ពេលក្រឡេកទៅរក Hacker ម្នាក់ដែលនៅអង្គុយទល់មុខតុ Lorenzo នៅឡើយ។ នាងនៅស្ងៀមវិញទុកឲ្យម្ចាស់ទីកន្លែងនេះដេញនាយច្រមុះស្រួចដោយខ្លួនឯង៖

«ទៅសិនចុះ!»

ជនបរទេសដែលលុះក្រោមបញ្ជា ចាកចេញមិនតវ៉ា។

Rose សម្លឹងមើល កំហឹងដែលលាក់ទុកក្នុងទ្រូងបុរសដ៏ស្រស់សង្ហានេះ។ គាប់ជួនគេជាមនុស្សមិនចេះញញឹមស្រាប់ សភាពការណ៍ហាក់កាន់តែស្រអាប់ឡើង។

«គេមិនបានពិភាក្សារឿងនេះជាមួយខ្ញុំទេ! ខ្ញុំក៏អត់ដឹងដែរថាគេសង្ស័យ Loren ដល់ថ្នាក់ចាយលុយច្រើនយ៉ាងនេះ ដើម្បីជ្រៀតចូលបណ្ដាញទិន្នន័យ របស់លោកដែរ!»

ឃើញ Lorenzo ក្តាប់មាត់នៅស្ងៀម នាងក៏នៅស្ងៀមបន្ទោសក្នុងចិត្តស្ងាត់ៗ៖

«មហាវីនឆេវឆាវទន្ទឹងទិស គង់តែមានរឿងទេ!»

កន្ទុយភ្នែកនាងឃើញបុរសនេះ លើកលេបថបមកបើក។ ម្រាមដៃរបស់នាយលឿនជាងស ង្វាក់បេះដូងនាង ដែលកំពុងរកមធ្យោបាយពន្លត់សង្គ្រាមរវាងអ្នកទាំងពីរ។

នាងខំរកពាក្យមកសម្រួលស្ថានការណ៍៖

«កុំប្រកាន់គេ! គេគ្រាន់តែចង់ការពារមុខរបរប៉ុណ្ណឹង!»

Lorenzo បញ្ចេញស្នាមញញឹមស្ងួត៖

«តែខ្ញុំមិនបានធ្វើអីវា ហើយវាមកប៉ះពាល់ខ្ញុំមុន ខ្ញុំក៏ត្រូវឲ្យវាដឹងដៃខ្លះដែរ មិនអ៊ីចឹង?»

គេនេះមិនដឹងថា ចេះពីជំនាញជ្រៀតចូលបណ្ដាញកុំព្យូទ័រក្នុងកម្រិតណាទេ តែម្រាមដៃស្ទាត់ជំនាញកម្រើកទន់ល្វៃ រហ័សសៃនរហ័សរបស់គេ កំពុងស្ថិតនៅលើ Key ធ្វើឲ្យចិត្តនាងបារម្ភ។

«យល់ដល់ខ្ញុំ! អត់ទោសឲ្យគេផងទៅ!»

នាងនិយាយអង្វរ ដែលពុំមែនជាទម្លាប់ពិតរបស់នាងទេ។

តាំងពីដើមមក Rose រស់នៅពឹងលើខ្លួនឯង ហើយនាងមិនដែលគិតថាជាតិនេះនឹងនិយាយអង្វរអ្នកណាម្នាក់ឡើយ។ លើកនេះប្រាកដណាស់គេដឹងថា នាងគិតដល់ម្ចាស់ ទើបនាងហាអង្វរនាយ។ ទោះយ៉ាងណា ក៏វាហាក់មានប្រសិទ្ធភាព ព្រោះអាណិកជនឈប់កម្រើកម្រាមហើយងើបមុខមកសម្លឹងនាង។ បបូរមាត់សិចស៊ីរបស់នាយដែលនាងលាក់ក្នុងទ្រូងរៀងរាល់រាត្រី ហើបមកកាន់ស្រីស្អាតនូវខ្លឹមសារសំណួរ៖

«ចែកឲ្យច្បាស់! Rose នៅខាងគេ ឬខ្ញុំ?»

នារីមេពិធីការឆ្លើយមិនរារែក៖

«យើងជាមិត្ត គេជាមេខ្ញុំ! ខ្ញុំនៅលើទូកតែមួយជាមួយគេ!»

ដៃបុរសនេះវាសអ្វីៗនៅលើតុ ឲ្យតែទើសមុខគេធ្លាក់មកខ្ទាតរប៉ាត់រប៉ាយ។ ចិត្តគេក្ដៅឆាបឆួលផ្ទុយពីផ្ទៃមុខគេដែលនឹងថ្កល់។

«Loren ចេះនិយាយខ្លួនឯងដែរ បើយើងមិនបានធ្វើអីគេ គេធ្វើអីធ្វើទៅ!»

បុរសនេះស្រាប់តែនិយាយសង្កត់សំឡេង៖

«ទៅប្រាប់វាឲ្យឈប់ មុនពេលខ្ញុំលេងវា!»

Rose ដកដង្ហើមមិនបានមួយកំណាត់ផង ទូរសព្ទនាងរោទ៍ឡើង។

ស្រីស្អាតដឹងថាជាអ្នកណា ទើបនាងដៀងភ្នែកសម្លឹងបុរសអាណិកជន មុនពេលចុចទទួល៖

«មហាវីន!»

នាងហៅមិនទាន់ផុតផង អ្នកមាឌធាត់កន្ទុក និយាយមកវិញលឿនរ៉ាវ ដូចមានខ្មោចព្រាយកំពុងដេញពីក្រោយ៖

«Rose អាម្នាក់ហ្នឹងមិនធម្មតាទេ បងជួលយុនប្រាវីតមកឆែកបណ្ដាញវា នេះត្រូវវាលេងវិញចាស់ដៃ! យុនប្រាវីតពូកែកម្រិតណា គិតមើល៍? ហេតុអីចាញ់របស់វាទៀត? ប្រយ័ត្នខ្លួន! នៅឆ្ងាយៗពីវាបានកាន់តែល្អ វាដឹងយើងសង្ស័យវាហើយ ប្រយ័ត្ន!»

Roseនិយាយខ្លីៗ៖

«ឈប់ធ្វើអីផ្ដាសទៅ! ចាំខ្ញុំខលទៅទៀត! ប៉ុណ្ណឹងចុះ! រវល់!»

នាងចុចបិទ ងើបមុខមករកបុរសនៅនឹងមុខខ្លួន។

Lorenzo នៅស្ងៀមមិនសម្លឹងនាង តែនាងនិយាយទៅកាន់គេ៖

«ចាំខ្ញុំនិយាយជាមួយ គេឲ្យច្បាស់ថាលោកគ្មានពាក់ព័ន្ធ! លោកគិតមើល គេព្រមបិទកម្មវិធីសមោសរនោះបណ្ដោះអាសន្នហើយ! អ្នកណាម្នាក់កំពុងប្រើប្រាស់កម្មវិធីរបស់ពួកខ្ញុំយកទៅចាប់ ស្រីៗ មុនក្រោយប៉ូលិសគង់តែមកដល់ទេ មហាវីនតក់ក្រហល់ គេគ្រាន់តែតក់ក្រហល់ពេក!»

«ទៅប្រាប់វាទៅ ជៀសខ្ញុំឲ្យហើយបើវាមិនចង់វេទនា!»

គេក្រោកចេញទៅតែនាងហៅឃាត់៖

«តែ Loren ក៏គួរឲ្យសង្ស័យដែរ!!»

បុរសមាឌ ខ្ពស់ សង្ហា ទប់ដំណើរ ហើយបែរមកសន្សឹមៗ ជាមួយចិញ្ចើមទាំងគូជ្រួញចូលគ្នា។ នាងដឹងថាគេខឹង តែនេះជាពេលដែលត្រូវបញ្ជាក់អ្វីៗគ្រប់យ៉ាងកុំឲ្យមានល្អក់កករ។ នាងបន្ថែមភ្លាមៗ៖

«Loren ត្រូវតែប្រាប់ខ្ញុំឲ្យច្បាស់លាស់ថាលោកមានពាក់ព័ន្ធរឿងស្រីៗអស់នោះកម្រិតណា?»

បុរសសង្ហាទប់ភាពសៅហ្មងមកវិញហើយច្រត់ចង្កេះ។ គេនិយាយខ្លីៗ៖

«ចេញទៅ!»

គេដេញនាងទាំងបោះបង់ចោលឃ្លាសំណួរនាងឲ្យនៅឃ្លេងឃ្លោងកណ្ដាលទន្លេងឿងឆ្ងល់។ ស្រីស្អាតគ្រវីក្បាលយឺតៗ៖

«អត់ទេ Loren! ខ្ញុំត្រូវការចម្លើយ!»

មេពិធីការរឹងរូស ចំណែក Lorenzoកាន់តែគ្មានមនោសញ្ចេតនា។ គេនិយាយតប៖

«ខ្ញុំមិនចាំបាច់ឆ្លើយអ្វីជាមួយអ្នកណាទាំងអស់!»

«លោកជាអ្នកជួបពួកគេចុងក្រោយមុនបាត់ខ្លួន លោកមិននិយាយអ្នកណាមិនសង្ស័យ?»

Lorenzo ខាំមាត់ដើរមកក្បែរ មុនពេលពោលពាក្យគំរាម៖

«អ្នកណាក៏ដោយ និយាយជាមួយប៉ូលិសរឿងខ្ញុំជួបស្រីៗអស់នោះ ដឹងតែមានរឿងជាមួយខ្ញុំមិនខាន!»

ឃើញនារីនៅភាំង ទើប Lorenzo ហាក់ដឹងខ្លួនមកវិញ ហើយងាកមុខចេញតែសម្ដីនៅតែគំរាម៖

«សូម្បីនាងក៏ដោយ!»

Rose ទម្លាក់ភ្នែកចុះពេលឮពាក្យប៉ុន្មានម៉ាត់ចុងក្រោយ។ នាងធ្វើមុខហាក់ហួសចិត្តខ្លួនឯងដែលកន្លងមកលបលួចសរសើរគេ ស្រលាញ់គេហើយស្ងប់ស្ងែងគេ។

បើមិននិយាយឌឺភ្លាមៗ ពុំមែនជាចរិតរបស់Rose ទេ៖

«អស្ចារ្យណាស់!!!! ថ្ងៃនេះទើបតែដឹងចរិតពិត របស់ពួកតារាសប្បុរសធម៌!»

ស្តាប់សម្តីនាងនិយាយ កាន់តែធ្វើឲ្យនាយក្តៅចិត្ត។

បុរសអាណិកជនម្នាក់នេះមិនតបតទើបចម្លែក គេនិយាយទាំងបែរខ្នង៖

«រឿងអស្ចារ្យមានច្រើនទៀត! ប្រសិនអ្នកណាប៉ិនចង់ដឹង ខ្ញុំនឹងធ្វើឲ្យវានោះស្គាល់ពាក្យអស្ចារ្យ!»

ទាំងបុរសនេះ ទាំងមហាវីន គ្មានត្រង់ណាខុសពីពួកអ្នកមាននានា ដែលនាងធ្លាប់ឃើញធ្លាប់ស្គាល់នោះទេ។ មួយម៉ាត់ឡើងនិយាយរឿងគំរាម និយាយរឿងអស្ចារ្យ រឿងសាហាវ ធ្វើម៉េចឲ្យតែបានខ្លាំង។ គោលដៅរបស់ពួកគេ គឺមានតែឈ្នះហើយនិងចាញ់។

ទោះជាមនុស្សស្រី នាងនៅតែមិនព្រមចុះចាញ់ការព្រមាន។ Rose និយាយតប៖

«ដូចគ្នា!»

គេងាកមុខមករឹង នាងក៏ប្រើភ្នែកមូលក្រឡង់ សម្លឹងទល់គ្នា។ ពិធីការនិយាយទាំងមិនដកភ្នែក ក្រែងគូសន្ទនាយល់ថា នាងភ័យខ្លាច៖

«សមោសរពណ៌ព្រះចន្ទ ជាកម្មវិធីញើសឈាមខ្ញុំ! អ្នកណាម្នាក់យកកម្មវិធីនេះទៅលាបពណ៌ជាប្រយោជន៍ផ្ទាល់ខ្លួនដឹងគ្នាជាមួយខ្ញុំ!»

នាងចាកចេញពីគេដោយបង្កប់ជម្ងឺ«ក្តៅចិត្ត» មកតាមមួយចប់ផ្លូវ។

ពេលរថយន្តលូនឆ្លងផុតក្លោងទ្វារបុរី ហើយផ្ទះខ្លួននៅមិនដល់ចម្ងាយប្រមាណ៥០ម៉ែត្រពីមុខ។ ភ្លើងជះមកពីខាងក្នុងភ្លឺចិញ្ចាច។

Roseជ្រួញចិញ្ចើមរអ៊ូ៖

«មហាវីន?»

Rose សួរខ្លួនឯង ព្រោះទូទាំងស្រុកខ្មែរ ក្រៅពីគេគ្មានអ្នកណាដែលស្និទ្ធស្នាលនឹងនារីនេះ ដល់ថ្នាក់អាចចេញចូលផ្ទះរបស់នាងបានតាមអំពើចិត្តឡើយ។

គេជាអ្នកជួលនាងមកធ្វើការ ហើយផ្ទះនេះគេក៏ជាអ្នកទិញឲ្យនាងស្នាក់ គេមានសោតែគេ កម្រនឹងមកកាន់ទីនេះណាស់ ប្រសិនគ្មានកម្មវិធី ឬគ្មានការអញ្ជើញ។

«ចុះឯណាឡានគេ?»

Rose សួរខ្លួនឯង មុនពេលអែបរថយន្តពីចម្ងាយ ហើយដៃស្រវ៉ារាវរកទូរសព្ទចុច។ ប្រសិនគេមិននៅទីនោះ តើអ្នកណាផ្សេងដែលបានមកដល់កន្លែងរបស់នាងទាំងយប់?

ផ្ទុយពីសេវាទូរសព្ទដ៏យឺតនៅស្រុកខ្មែរ មហាវីនពិតជាលើកទទួលយ៉ាងរហ័ស។

«អាឡូ Rose!»

សំឡេងអ្នកមានធាត់កន្ទុក មិនបានប្រែប្រួលអ្វីខុសប្រក្រតីទេ ក្នុងការសម្គាល់របស់នាង។ ដោយមិនចាំបាច់ «អាឡូ» នារីស៊ីវិល័យចាប់ផ្ដើមសួរ៖

«មហាវីននៅឯណា?»

ភាគទី១៥

«នៅផ្ទះ Rose ហ្នឹងឯង!»

នាងបញ្ចេញអាការៈហាក់ត្រិះរិះ ពីអ្វីមួយយ៉ាងជ្រាលជ្រៅ។

ពេលឡានលូនដល់កន្លែងវា នាងប្រញាប់រត់ចូលទៅ។

ពិតដូចការគិតរបស់នាងកាលពីក្នុងឡាន ទោះបីសំឡេងនាងបញ្ជាក់ភាពធម្មតា ប៉ុន្តែស្ថានភាពមហាវីននៅនឹងមុខនាង គឺមិនធម្មតាដូចរាល់ដងទេ។

គេស្លៀកខោវប៊យ និងអាវយឺត ក្រាស់ដូចត្រៀមចេញដំណើរទៅណាឆ្ងាយ។

បន្ទាន់នោះ ស្រីស៊ីវិល័យក្រឡេកភ្លាម ឃើញប្រអប់ធំមួយ ទុកចោលលើតុក្បែរសាឡុងដែលប្រាកដថាគេជាអ្នកបញ្ជូនមក។

«ស្អីគេហ្នឹង?»

Rose សួរដោយសម្លឹងទៅប្រអប់នោះ។

«វត្ថុបុរាណ! ថ្លៃសម្បើមណាស់! យកមកផ្ញើឯងសិន Rose!»

ដល់ពេលនាងសម្លឹងគេពីលើចុះក្រោម មុនពេលបែរទៅខាងក្រៅសម្លឹងតាមបង្អួច។ សួនស្ងាត់ជ្រងំ ហាក់បីដូចជាបរិយាកាសដែលដែលនាងកំពុងទទួលរង។

«មហាវីនទៅណា! ហើយឯណាឡាន?»

គេហាក់ស្ងើតស្លក់អេះអុញចំពោះសំណួរនេះ។ ជាលើកដំបូងដែលអ្នកមានដូចគេបង្ហាញភាពមិនស្រណុកនៅចំពោះមុខនាង។ Rose និយាយបន្ថែម៖

«អូខេ! អង្គុយមករកទឹកឲ្យញ៉ាំហើយប្រាប់តាមសម្រួលមក មានរឿងអី?»

នាងលើកទឹកមកដល់ ឃើញគេលើករបស់មួយចេញពីក្នុងប្រអប់។

វាជារបស់ដែលនាងនឹកមិនឃើញថាធ្លាប់ឮមហាវីននិយាយ ឬមួយក៏ធ្លាប់ឃើញនៅផ្ទះគេនោះទេ។

រូបរាងវត្ថុនេះមិនសមជាផើងផ្កា ក៏មិនសមជាចូ ប៉ុន្តែហាក់មានក្បាច់ក្បូរជាច្រើនសមជាគ្រាប់ស្រូវ ប៉ុន្តែដោយសារវាចាំងពន្លឺ នាងមើលច្រឡំថាជាពំនូកត្បូង។

នាងហុចកែវទឹកទៅបុរសនេះភ្នែកនៅតែផ្តោតលើវត្ថុដែលមានពណ៌សទឹកដោះគោ ហើយភ្លឺយង់មិនគួរឲ្យដកភ្នែកចេញសោះ។

«ម៉េចក៏មួយ៥ម៉ឺនដុល្លារដែរ!»

«ថ្លៃលើហ្នឹងបីដង!»

គេនិយាយស្រាលៗ ធ្វើឲ្យនាងភ្ញាក់លូកដៃទៅស្ទាប។ ត្រជាក់ស្រឹប... នាងចុចម្រាមដៃសង្កត់ មុនពេលប្រើចុងម្រាមសង្កត់ម្តង...

Rose គ្រវីក្បាល៖

«មិនមែនថ្មកែវ មិនមែនពេជ្រ ហើយក៏មិនមែនភ្លុក!»

មហាវីនដកដង្ហើមធំនិយាយកាត់៖

«មរកត យកមកពីឥណ្ឌាសល់តាំងពីរាជវង្សកាន!»

Rose ជញ្ជក់មាត់ ហើយយកម្រាមទាំង១០ទៅផ្ទឹបលើរូបចម្លាក់។ វត្ថុនេះមានកម្ពស់ប្រមាណជាមួយចំអាមមនុស្សចាស់ ប៉ុន្តែចំណុចកណ្ដាល ខ្ពស់ស្រួចស្លឹមទៅលើមួយចំអាមទៀត។

នាងសាកលើកវារលាក់ទម្ងន់ ទើបស្រីស្អាតងក់ក្បាលផ្ងក់ៗទទួលស្គាល់៖

«មរកតពណ៌ស តាំងពី៣០ឆ្នាំមុនគ្រឹះសករាជ! ធ្លាប់ឮ មិនដែលគិតថាមានពិតមែនទេ ហើយមានក្នុងដៃខ្មែរយើង!»

មហាវីនមើលនាទ្បិកា រូបរាងគេគឺអន្ទះសា ជាងចិត្តនាងដែលកំពុងត្រេកត្រអាលនឹងវត្ថុនេះ។

«ដេវីដ មកយកខ្ញុំឥឡូវហើយ!»

នាងទាញអារម្មណ៍មកវិញ រវាងឈ្មោះលេខាដែលនាងយល់ថាជាមនុស្សកម្ទេចមនុស្ស ហើយនឹងវត្ថមានវត្ថុដ៏ប្រណីតក្នុងគេហដ្ឋានរបស់ខ្លួន។

«ហើយគិតទៅណា? ចំណែករបស់នេះ មិនយកទៅធនាគារទៅ?»

គេឱនមកខ្សឹបរារាំង យ៉ាងអន្ទះសា៖

«កុំៗៗៗ! នៅស្រុកខ្មែរ គ្មានអ្នកណាដឹងរឿងនេះទាំងអស់! ពីមុនមានតែខ្ញុំ ឥឡូវមាននាងម្នាក់ទៀត! ពេលរឿងស្ងប់ ខ្ញុំបកមកវិញ ខ្ញុំមកយកទៅវិញ!»

នាងមានអាការៈហាក់សប្បាយចិត្តភាំង ព្រោះទើបនឹងដឹងថាពេលអាសន្ន នាងជាមនុស្សតែម្នាក់គត់ដែលគេពឹង។សម្ដីគេ នាងយល់។ បុរាណវត្ថុនេះ គ្មានអ្នកណាស្គាល់ទេ។ យកទៅផ្សារទួលទំពូងច្រើនណាស់គេឲ្យប៉ុន្មានពាន់ដុល្លារ ព្រោះភាពជាត្បូងមរកតរបស់វា ប៉ុន្តែប្រវត្តិរបស់វាគឺមានតម្លៃមហាសាល។

«នៅឡុងដុង ខ្ញុំធ្លាប់រៀបចំពិធីដេញថ្លៃរតនវត្ថុពីរដងដែរ! វត្ថុរាជវង្សតែងតែមាន ត្រាឬសញ្ញាសម្គាល់! បង្ហាញមក មហាវីន!»

គេដកដង្ហើមធំលើកផ្ទារបង្ហាញអក្សរបុរាណរបស់ឥណ្ឌានាចុងបង្អស់នៃគែមផងនេះ។ ស្រីស្អាតភាំង លើសដើមជាមួយភាពសក្ការដែលនាងទទួលអារម្មណ៍ដឹង តាមរយៈសំណឹកដែលនៅសេសសល់ខ្លះៗក្បែរត្រាបុរាណតូចស្រួចមួយ។

«មិនដឹងវារត់លូនមកយ៉ាងម៉េចខ្លះទេវត្ថុនេះ!»

នាងនិយាយរអ៊ូៗ តែមហាវីនហាក់មានពេលកាន់តែខើច។ អ្នកមានកន្ទាត់ ទាញដៃនាងយកមកខ្សឹបៈ

«ទុកវាឲ្យល្អ កុំធ្វើអី ពិសេសដាក់វាកុំឲ្យអ្នកណាសង្ស័យ!»

នាងដកភ្នែកពីវត្ថុពិសិដ្ឋហើយសួរវិញបន្ទាន់៖

«មហាវីនទៅណា?»

«ខ្ញុំចេញទៅក្រៅមួយរយៈ! យប់នេះចេញទៅកូរ៉េសិន បើនៅតែពិបាកចេញទៅហូឡង់មួយរយៈ! មើលក្រុមហ៊ុនផង ខ្ញុំមានរង្វាន់!»

នាងជ្រួញចិញ្ចើមតប៖

«កុំគិតរឿងលាភសក្ការៈ មហាវីន! និយាយមកលោកពាក់ព័ន្ធរឿងចាប់ស្រីៗអស់ហ្នឹងមែនដែរអត់? អ្ហះ? និយាយភ្លាម?»

មហាវីនហាក់ធុញណាស់ដែលគេមិនឆ្លើយក៏មិនកើត។ នាយនិយាយខ្សឹបៗល្មមឮពីរនាក់៖

«អត់ទេ! មានឡប់អត់? ខ្ញុំចាំបាច់ទៅធ្វើរឿងខុសច្បាប់បានមានបាយស៊ី? មនុស្សកំពុងជោគជ័យធ្វើអីអ៊ីចឹងធ្វើអី?»

«ចុះរត់ចោលស្រុកធ្វើអី?»

«អា Lorenzo វាចាត់មនុស្សតាមសម្លាប់ខ្ញុំ!»

នាងនៅស្ងៀម តែចិត្តនាងកំពុងវិល។ Rose មិនមានសំណួរប៉ុន្តែភ្នែកនាងបង្កប់ចម្ងល់១០០ឃ្លា។

«ឡានខ្ញុំដាច់ហ្វ្រាំង ព្រឹកមិញអាដេវីដចេញទៅធ្វើការក្រៅ វាយកឡានខ្ញុំទៅអាឡានស នាងដឹងទេ នៅសុខៗហ្វ្រាំងមិនស៊ីទេ!»

Rose កាន់តែរងើរងើ៖

«ហើយម៉េចបានលេខាភ្លើៗនោះវាអត់អី?»

មហាវីនខ្សឹបៈ

«វាលោតចុះ!»

នាងក្រពាត់ដៃមួហ្មង។ Lorenzo ពិតជាបានខឹង នាងឃើញស្ថានភាពគេផ្ទាល់ភ្នែក  តែគេមិនមែនគ្រាន់តែប៉ុណ្ណឹងចង់សម្លាប់មហាវីន?

«ហេតុអីគេចាំបាច់ធ្វើអ៊ីចឹង? មិនមែនគេទេ!»

មហាវីនក្ដាប់មាត់ខឹង ដែលមនុស្សរបស់ខ្លួនចុងក្រោយនៅតែជឿអ្នកផ្សេង។ គេខាំមាត់គំហកមិនចង់ឲ្យសំឡេងលាន់ឮពេក៖

«ស្គាល់វាយូរប៉ុនណាហើយអ្ហះ? វាមកពីណា ប្រវត្តិយ៉ាងម៉េច? ហើយវាយកលុយមកជះនៅស្រុកខ្មែរច្រើនម្លឹងៗ វាមានបំណងស្អី?»

Rose ងាកមុខចេញព្រោះចចេសការពារភាគីម្ខាងទៀត៖

«អត់ទាក់ទងនឹងយើងទេ!»

«អត់ទាក់ទង!? អ្ហះ? ស្រីៗបាត់ខ្លួនទាំងអស់ ក្រោយពេលជួបជាមួយវា បើមិនទាក់ទងនឹងវាមានតែទាក់ទងនឹងយើង!»

នាងទម្លាក់ដៃចេញពីទ្រូង ហើយដង្ហើមចាប់ផ្ដើមញាប់។

អ្នកណាម្នាក់នៅក្រៅបង្អួចធ្វើឲ្យនាងបែរទៅរឹងទាំងសង្កត់សំឡេង៖

«អ្នកណាហ្នឹងមហាវីន?»

មហាវីនបង្ហាញភាពភ័យស្លន់ តាមរយៈទឹកមុខ ហើយភ្នែកទាំងគូបើកប៉ុនពងមាន់។

គេថយក្រោយ ដៃរាវរកវត្ថុបុរាណមកកាន់។ របស់នេះធ្ងន់គួរសម បើប៉ះអ្នកណាហើយ ពិបាកក្រោក មកវិញមិនខាន ប៉ុន្តែចុះបើមហាវីន ពិតជាកំពុងមានគេប្រដេញ ហើយពួកនោះមានកាំភ្លើង?

នាងរត់ទៅអែបទ្វារ ឯគេរត់មកតាមក្រោយ។

ស្នូរគោះទ្វាលាន់ឡើង....

«ខ្ញុំទេ!»

មហាវីនធូរទ្រូង ហើយដាក់វត្ថុបុរាណចុះវិញទាំងហត់គឃូស។ សំឡេងលេខាដេវីដ ធ្វើឲ្យបុរសអ្នកមានធូរចិត្ត ភ្នែករំពៃរកកន្លែងដាក់មរកតទុក សមរម្យទើបលូកដៃមួលសោបើកទ្វារ។

គ្រានោះ Roseដាក់បាតដៃពីលើយាត់។

នាងឱនខ្សឹបសួរគេ៖

«ចេញពីនេះទៅណា? ទុកចិត្តវាម៉េះ?»

មហាវីនមិនមាត់ គេឲ្យសញ្ញាជាកាយវិការថា «មិនអីទេ» ខណៈអ្នកដែលនៅក្រៅទ្វារអស់ពីគោះដូរមកចុចកណ្ដឹងវិញម្ដង។

គេចចេសចង់បើក នារីម្ចាស់ផ្ទះក៏ថយចេញឲ្យបើក។

លេខាពិតជាបង្ហាញខ្លួន ដោយស្ងើតស្លក់ ជាងអាការៈរបស់ថៅហ្វាយនាយទៅទៀត។

គេរុញទ្វារបិទ មិនខ្វល់ក្រសែភ្នែកពិនិត្យពិច័យរបស់ Rose ទេ។ ដេវីដខ្សឹបខ្សៀវដាក់មហាវីន៖

«សំបុត្រទិញបាន តែព្រឹកព្រហាមបានចេញ!»

មហាវីនញាក់មុខបន្ទោស៖

«ល្ងង់ណាស់ មិនចាំសុំទិញអ្នកដំណើរឡើងយប់នេះទៅ! ឲ្យលុយគេឲ្យច្រើនទៅ!»

ដេវីដងក់ក្បាល៖

«ចេញទៅព្រលានសិនចាំគិត!»

«អត់ទេ! ខ្ញុំហៅប៉ូលិស!»

Rose និយាយពីចម្ងាយទាំងដៃកាន់ទូរសព្ទស្រាប់ តែមហាវីនរត់ទៅដណ្ដើមយ៉ាងរហ័ស ទាំងបន្ទោសផង៖

«ឆ្កួតទេហ្អី?»

Rose និយាយម៉ឺងម៉ាត់៖

«មានតែប៉ូលិសទេ អាចធានា សុវត្ថិភាពមហាវីន! កុំទុកចិត្តអ្នកណាទាំងអស់!»

ដេវីដឌិនលំទោនធ្វើមិនឮ មិនឃើញកែវភ្នែកនិងសម្ដីស៊ុកសៀតដែលនាងជះមក។

មហាវីននៅតែមិនលែងទូរសព្ទ ហើយពន្យល់៖

«នាងស្គាល់ប៉ូលិសស្រុកខ្មែរមិនច្បាស់ជាងខ្ញុំទេ Rose!»

«ចង់មានន័យថាម៉េច?»

មហាវីនគ្មានសុទិដ្ឋិចំពោះប៉ូលិស តែគេហាក់គ្មានពេលនិយាយ។ បុរសធាត់ងាកទៅរកកូនថៅហើយចេញបញ្ជា៖

«ចេញដំណើរ!»

ដេវីដឌិនកាយចាកចេញទៅរកឡាន ឯRose នៅតែស្ទុះមកក្បែរមហាវីន ហើយនិយាយដោយមិនអស់ចិត្ត៖

«លោកបាត់ខ្លួនទៅ ប៉ូលិសគិតយ៉ាងម៉េច? គេអាចចោទថាលោកបានធ្វើខុសហើយរត់ចោលទោស!»

«អ៊ីចឹងហើយ Rose បានខ្ញុំមិនហៅនាងទៅជាមួយ! គោលដៅគឺខ្ញុំមិនមែននាងទេ បើនៅ ខ្ញុំអាចនឹងត្រូវស្លាប់ក៏ថាបាន នាងនៅលាងភាពស្អាតស្អំឲ្យខ្ញុំនិងកម្មវិធីរបស់យើង!»

ឡានមកដល់កៀកទ្វារ ហើយម៉ាស៊ីនស្រាលស្ងើកសឹងមិនឮអ្វី។

នាងងក់ក្បាល ទទួលបញ្ជាដែលគេផ្ដាំ។

បុរសនេះឡើងទៅលើរថយន្ត ហើយរថយន្តក៏ថយទៅក្រោយយ៉ាងរហ័ស និងដោយភាពប៉ិនប្រសប់ របស់អ្នកបើក។ នាងសម្លឹងគេរហូតដល់ផុត កន្ទុយភ្នែកទើបរលះរលាំងបកត្រឡប់ចូលផ្ទះវិញ ក្នុងសភាពប្រញាប់ប្រញាល់នឹងអ្វីមួយ។

វគ្គ លេងភ្លើងច្រើនគង់អីរលោក

នៅលើផ្លូវក្រោមស្បែអន្ធការ មហាវីនមិននិយាយអ្វីជាមួយលេខាដែលពេលនេះបំពេញការងារ ជាអ្នកបើកបរនៅឡើយ គេហាក់ដូចជាកំពុងផ្តោតយ៉ាងជ្រៅលើគម្រោងផែនការអ្វីមួយ។

សំណួរដេវីដលាន់មកជ្រែកកាត់ស្ថានភាពស្ងប់ តែមិនស្រណុក៖

«បើទៅដល់ យើងទិញសំបុត្រមិនបានមែនគិតយ៉ាងម៉េច?»

លេខាដាក់សំណួរមកហើយលបលួចសម្លឹងមុខមុខថៅហ្វាយតាមកញ្ចក់។ មហាវីនញញឹមយ៉ាង សាហាវខុសពីកាយវិការភ័យៗ ដែលគេបានសម្តែងមុននេះ។ លេខាដេវីដបង្វិលគ្រាប់ភ្នែក រិះគិតមុនពេលសួរបញ្ជាក់៖

«ថៅកែវីន អ៊ុំចឹងរឿងទៅព្រលានយន្តហោះ ក្លែងក្លាយទេហ្អី?»

មហាវីនញញឹម៖

«មនុស្សដូចខ្ញុំចង់បានសំបុត្រយន្តហោះជិះ ស្មានថាវេទនាដល់ថ្នាក់នេះ?»

ដេវីដជូតញើស។

មហាវីនកាន់តែបានចិត្ត ព្រោះនាយយល់ថាការសម្តែងរបស់ខ្លួនគ្មានអ្នកណាអាចមានបញ្ញាកាត់យល់ដល់ទេ។

ដេវីដនៅស្ងៀមហាក់បីដូចជាគេកំពុងតែជឿថា ថៅហ្វាយក្រអឺតម្នាក់នេះ នឹងនិយាយប្រាប់គេបន្តទៀត។

ពិតដូចការគិត មហាវីនចាប់ផ្តើមចេញបញ្ជា៖

«ដឹកខ្ញុំទៅដាក់នៅក្លឹបអោបស្រីៗសប្បាយៗ! ចេញពីក្លឹបខ្ញុំទៅដេកផ្ទះ វិញធ្វើដូចខ្ញុំអត់ខ្វល់អី! ចំណែក Rose ឲ្យគ្នាយើងតាមឲ្យជាប់ថា នាងចេញទៅជួបអាម្នាក់នោះពេលណា!»

«ម៉េចក៏ថៅកែគិតថា ការបាត់ខ្លួនស្រីៗ ជាស្នាដៃអាណិកជននោះ?»

មហាវីនក្អាកក្អាយតែមិននិយាយតបអ្វីសូម្បីតែមួយម៉ាត់ណាក្តី។ គោលដៅមហាវីនពេលនេះ សត្រូវទីមួយរបស់គេចំពោះមុខគឺតារាសប្បុរសនោះមិនថាហេតុផលអ្វីក៏ដោយ។ក្នុងរូបភាព

ផ្សេងៗគ្នា ទោះបីថាថ្ងៃក្រោយទៅការពិតបញ្ជាក់ថា lorenzoមិនបាននៅពីក្រោយការចាប់ស្រីៗទាំងនោះ ក៏វត្តមានគេ មិនអាចឃាត់មិនឱ្យអ្នកផងកើតចិត្ត ច្រណែនបាននោះដែរ។

អាណិកជនដ៏មានមហាសាលម្នាក់នោះ ជាបន្លាក្នុងកែវភ្នែក មហាវីនតាំងពីឃើញគេមកជាន់ភ្នំពេញដំបូង។

ពេលនេះ គេធ្វើឬមិនធ្វើចាំបាច់អីខ្វល់ច្រើន?

តួនាទីយើងពេលនេះគឺ បើអាចបង្វិលយ៉ាងណា បង្កើតរឿងដាក់គេឱ្យក្លាយជាឧក្រិដ្ឋកម្មចាប់ស្រីៗបានពិតមែនមិនរឹតតែល្អ?

ដេវីដធ្វើមុខរងើរងើហាក់កំពុងវិលខ្វាល់នឹងស្ថានការណ៍ល្បិចប៉ះល្បិចអស់ទាំង គេបត់ចង្កូតវិលត្រឡប់ទៅរកប្រជុំជនកណ្តាលក្រុងវិញបង្ហាញថាគេទើបនឹងដឹងសម្តីមហាវីនប្រាប់ Rose មុននេះគឺកុហកទាំងអស់។

«មហាវីនយករឿងប្រាប់ Roseមិនខ្លាចគេក្បត់ទេ?»

សំឡេងដេវីដសួរ ទាញបុរសអ្នកមានឱ្យបកមករកការសន្ទនាវិញ។ គេរិះគិតហើយប្រយ័ត្នប្រយែងក្នុងការឆ្លើយតបៈ

«បើនាង Rose ក្បត់យើង ហើយយករឿងយើងទាំងអស់ទៅប្រាប់អាម្នាក់នោះ យើងនឹងបានលេសថា ពីរនាក់វារួមដៃគ្នា ផ្សំគំនិតរៀបគម្រោងបិទកម្មវិធីសមោសរពណ៌ព្រះចន្ទរបស់ខ្ញុំ! »

«ចុះបើ Rose មិនបានក្បត់?»

មហាវីន ក៏មិនទ័លក្នុងការឆ្លើយតបទៀតៈ

«ម៉េចក៏និយាយជាន់កែងខ្លួនឯង? ម្សិលមិញឯងជាអ្នកឲ្យយើងដឹងពីរឿងនាងជាមួយអាអាណិកជននោះ មិនអ៊ីចឹង? ឯងមែនទេដែលប្រាប់យើងថា អ្នកណាម្នាក់ដូចជាកំពុងមានផែនការលេងយើង?

មនុស្សបាត់៤នាក់ សុទ្ធតែមុនឬក្រោយបានចូលរួមកម្មវិធីយើង! ទោះបីអ្នកចូលសមោសរពណ៌ព្រះចន្ទសុទ្ធតែចូលជាសម្ងាត់តែពេលនេះ កូនអ្នកមានអស់ហ្នឹងនៅសុខៗបាត់ខ្លួន

ប៉ូលិសចាប់ផ្ដើមស៊ើបល្អិតគ្រប់រឿង គ្រប់សកម្មភាព! មុនក្រោយប៉ូលិសគង់តែដឹង ហើយគេគង់តែមកដល់កន្លែងយើង! បើមិនមែនគម្រោងការរបស់វាកម្ចាត់យើង ជាអ្វីវិញ?!»

ឃើញដេវីដនៅស្ងៀមគេដាក់បន្ថែម៖

«មិញឯងសួរយើងសំណួរមួយផ្សេងទៀតថា ចុះបើ Rose មិនមែនបក្សពួកវា? ចម្លើយស្រួលណាស់! បើមែន ដំណាក់កាលនេះ នាងនឹងសង្ស័យ វាហើយជម្រះបញ្ជីលើវាឲ្យយើង!យើងនៅតែទទួលផលស្រួល!»

ជនកន្ទាត់សំអាងអីដែលហានលាតត្រដាងមធ្យោបាយមុខពីរសងខាងរបស់ខ្លួនប្រាប់ដេវីដម្នាក់នេះ។

ជួនកាលមកពីគម្រោងការ ដែលដាក់ចិត្តសំអប់ទៅលើLorenzoពេកបានជាខ្វះការប្រុងប្រយ័ត្នលើអ្នកផ្សេង។ គេនិយាយមួយៗ ក្រោយពីឃើញដេវីដសំងំមិននិយាយ៖

«អ៊ីចឹងយប់នេះយើងឃ្លាំមើលតើនាងនោះចេញទៅរក Lorenzo ដែរអត់? បើវាអត់! យើងនឹងបង្កើតរឿងលើខ្លួនយើង ហើយចូលទីដេកពេទ្យ! ចំណែកអាមួយនោះវានឹងត្រូវទទួលខុសត្រូវជាមួយ Roseព្រោះRoseនឹងគិតថាខ្ញុំរបួសព្រោះវាជាអ្នកធ្វើ ! ដល់ពេលនោះ បើ Rose ទៅរកវាសួរនាំទៀត ពេលនាងចេញមកវិញយើងធ្វើឱ្យ Roseត្រូវ រងគ្រោះ បន្ថែមមួយជាន់ទៀត គឺបានន័យថា វាបំបិទមាត់នាង!»

លេខាលើកមេដៃសរសើរចៅហ្វាយជំនួសឲ្យសម្ដីធ្វើឱ្យជននេះញញឹមបិទមាត់មិនជិតរីកថ្លើមប៉ុនចង្អេរ។

គឺចរិតមហាវីន មិនខុសពីអ្នកមានជាច្រើនលើលោកនេះទេ គេចូលចិត្តណាស់ឱ្យអ្នកក្បែរខ្លួនទុកគេថាជាមនុស្សពូកែ ជាប្រភេទមនុស្ស«អស្ចារ្យ»កម្ររក។

បន្ទាប់ពីចាយវាក្នុងក្លឹបអស់ចិត្តអស់ចង់ កណ្ដាលយប់ គេជូនមហាវីនវិលមកដេកផ្ទះផ្សេងមួយទៀតរបស់គេដែលកន្លងមកមិនដែលមានអ្នកណានៅថែទាំ ហើយភាគច្រើនទុកសម្រាប់ការហៅនារីៗកំណាន់មកកំដរម្ដងម្កាល។

គេចូលដំណេកទាំងញញឹម ព្រោះកំពុងមានជំនឿចិត្តខ្ពស់លើការងារ កសាងសេណារីយោកុហកដើម្បីរុញLorenz ឱ្យចូលអន្ទាក់មែនទែនតែម្ដង....

.....បានមួយស្រទ្បេត ទូរសព្ទដាស់មហាវីនឲ្យភ្ញាក់ពីដំណេក។

គេមើលម៉ោងលើជញ្ជាំងចុងជើង ដឹងថាជាពេលណាត់គ្នាសម្រាប់គម្រោងការបន្ទាប់...

«ម៉េចហើយដេវីដ!»

សំឡេងលេខារាយការណ៍មកវិញ៖

«ស្រីនោះមិនចេញទៅណាទាំងអស់! បិទភ្លើងរាប់ម៉ោងហើយគ្មានសកម្មភាពទេ!»

មហាវីនរិះគិត។

គេមិននៅយូរទេ ព្រោះដឹងថា កូនចៅរង់ចាំស្ដាប់បញ្ជា។ គេងក់ក្បាលហើយសម្រេចចិត្តមុនពេលនិយាយ៖

«បានហើយ! ចូលឆាកទីពីរឲ្យពួកហ្នឹងឡើងមក! ធ្វើឲ្យដូចមែនទែន! ពេលអញរបួស Rose នឹងគិតថា វាជាអ្នកធ្វើ!»

គេថយមកវិញ សម្លឹងទូរសព្ទមួយគ្រឿងទៀតទាំងញញឹម។

គេលើកវាមកចុចបើក បន្ទាប់ពីបិទប៉ុន្មានម៉ោងមកហើយ។

SMSរបស់នាងលោតមកជាច្រើនលើកច្រើនសារ...

«មហាវីន ម៉េចខ្ញុំខលលោកមិនចូល» «អូខេ! បើលោកoffហើយ ទៅដល់កាលណាឃើញសារខ្ញុំត្រូវសរសេរមកវិញ! ខ្ញុំបារម្ភ!» «មហាវីន! លោកនៅឯណាហើយ?»...

អ្នកមានសម្បូរល្បិចញញឹមដាក់SMSហើយនិយាយម្នាក់ឯង....

«សុំទោសដែលខ្ញុំប្រើប្រាស់នាង Rose! បើនាងស្មោះខ្ញុំក៏ដោយ ស្ដាយដែលខ្ញុំមិនមែនជាមនុស្សចិត្តទន់ គិតស្រីជាងផលប្រយោជន៍!»

គេសើចម្នាក់ឯងក្អាកក្អាយជួនពេលស្នូរកណ្ដឹងទ្វារលាន់មក...

ឆាប់ម៉េះ?

គេគិតម្នាក់ឯង... ទាំងដៀងភ្នែកសម្លឹងទ្វារ...

ភាគទី១៦

ដល់ពេលដែលមហាវីន ត្រូវដើរតួជាអ្នករងគ្រោះហើយ។ តាមការគ្រោងទុក គេដឹងជាស្រេចថាអ្វីនឹងកើតឡើង ហើយអ្វីទៅនឹងជាលទ្ធផល ដូច្នេះមានតែអូសទូកបណ្ដោយតាមទឹក។

«អ្នកណា?»

គ្មានចម្លើយ ។

គេហដ្ឋានទុកសម្រាប់ណាត់ស្រីស្នេហ៍ហារយរបស់នាយគឺនៅកន្លែងស្ងាត់ស្រាប់ហើយ ថែមទាំងនៅឆ្ងាយពីគេឯងទៀត។

វាជាប្រភេទកូនវីឡាតែមួយជាន់គត់ រុំព័ទ្ធដោយកញ្ចក់ហើយ អែបកៀកនឹងមាត់ស្រះ ដែលរៀបចំឱ្យដូចធម្មជាតិ។ នៅជុំវិញផ្ទះ ដីជម្រៅប្រមាណ៥០ម៉ែត្រជាសួនច្បារអស្ចារ្យ លាតសន្ធឹងបង្អួតភាពស្ដុកស្ដម្ភរបស់នាយ ហើយកម្លាំងសន្តិសុខមានតែនៅឯក្លោងទ្វារមុខប៉ុណ្ណោះ។

គេដឹងថា គ្មានអ្នកណាមកចុចកណ្ដឹង ក្រៅពីសកម្មភាពពួកដៃជើងរបស់ជំនួយការឈ្មោះដេវីដដែលធ្វើតាមបញ្ជាខ្លួនកាលពីព្រលប់ហ្នឹងទេ អ៊ីចឹងហើយត្បិតថាគ្មានឮចម្លើយអ្នកណាម្នាក់តបមក ក៏នៅតែក្រោកទៅបើកទ្វារមើល។

ស្ងាត់សូន្យគ្មានឃើញអ្នកណាសោះ…

ក្រដាសមួយ ទុកចោលនៅចុងជើងជាមួយរូបក្បាលខ្មោចគូរឡើងដោយប្រើហ្វឹតពណ៌ក្រហម។ អក្សរមួយជួរនៅខាងក្រោមប្រើពណ៌ខ្មៅអានមួយប៉ប្រិចភ្នែកក៏អានចប់ទៅហើយ។ដៃជើងមហាវីន មនុស្សកំពូលក្រឡេចក្រឡុច កំពូលអំនួត ពេលនេះស្រាប់តែចេះចុះសីតុណ្ហភាពត្រជាក់ដោយខ្លួនវា? ព្រោះអ្វី? ព្រោះពាក្យមួយឃ្លានោះមានន័យថា « ឯងដល់ពេលត្រូវទៅហើយ!»។

បុរសអ្នកមានផ្ដើមចេះពិភាល់…

វីឡាដែលគេរស់នៅមួយនេះស្ងាត់ស្ងៀមទៅតាមពេលវេលានឹងបទវិន័យដ៏តឹងតែងរបស់គេ ហើយកុំថាឡើយមុខអ្នកដែលគោះទ្វារអម្បាញ់មិញសូម្បីស្រមោលសត្វល្អិតមួយក៏គ្មានផង។

«លេងដូចមែនទែន!»

គេគិតទាំងចិត្តមួយប្រឹងសប្បាយដើម្បីកម្លាខ្លួនឯង ឯចិត្តមួយវិញទៀតចាប់ផ្ដើមខ្វល់ចម្លែក… ។ អារម្មណ៍ដែលត្រូវគេលបធ្វើឃាតពិតជាពិបាកដល់ម្លឹងមែន?

ទោះបីដឹងហើយថាគ្រាន់ជាល្ខោន ក៏បែរខ្នងចូលមកវិញហើយរុញទ្វារដ៏ធំមាំនោះបិទទៅវិញគ្រឹប។

តែគេមិនរហ័សស្មើនឹងអ្នកដែលទុកក្រដាសនៅចុងជើងមិញនេះសោះ។

វត្ថុអ្វីមួយសើមហើយក្រអូបហាងបុកមកចំពីមុខចូលដល់ក្នុងប្រអប់មាត់ ធ្វើឲ្យខ្លួនត្រូវគាំងចលនាព្រោះហាមិនបានបិទមាត់មិនកើត និយាយមិនចេញ។

«ក្រូចបេះក្រោយផ្ទះឯង ចូលមាត់ ទាំងមូលអ៊ីចឹងឆ្ងាញ់ដែរថៅកែ?»

មហាវីន បើកភ្នែកក្រឡោតសម្លឹងមនុស្សប្រុសបីបួននាក់ដែលនៅឈររាយគ្នាពេញបន្ទប់។ ទោះបីគិតថាជាឆាកល្ខោន តែវាក៏មិនងាយស្រួលនឹងសម្ដែងដែរនៅពេលដែលក្រូចទាំងផ្លែត្រូវញាត់មកចុកប្រអប់មាត់ ហើយដៃត្រូវចងស្លាបសេកទៅក្រោយ។

គេខំរើតាមធម្មជាតិរបស់មនុស្សជាប់ក្នុងការទន្រ្ទាន ប៉ុន្តែនរណាម្នាក់ដាក់មួយកែងដៃចំពីក្រោយខ្នង អួលសឹងវិលខ្វាល់ដួលខ្ពាកទៅលើឥដ្ឋបាន ដូច្នេះគេធ្វើពុតជាទន់ជើងដួលខ្ពាកតែម្ដង។

នៅក្នុងការឈឺចាប់មិនធ្លាប់ជួបក្នុងជីវិត មហាវីនព្រិលភ្នែកតែចិត្តនៅស្វាង។ បុរសនេះសច្ចាភ្លាមៗថា មនុស្សទាំងអស់នេះនឹងត្រូវធ្ងន់វិញមិនខានពេលឆាកល្ខោនរួចរាល់។

«ពួកអាបំបង់បាយ! ឲ្យវាលេងបញ្ឆោតគេ វាលេងវាយឯងមែនទែន ដូចមានគំនុំពីពេលណាមកមិនដឹង!»

មហាវីនខំសម្គាល់រកនឹកមុខពួកនេះ ប៉ុន្តែគ្មានអ្នកណាម្នាក់សមថាជាកូនចៅដែលខ្លួនធ្លាប់ស្គាល់នោះទេ។ ដៃអ្នកណាម្នាក់ឈោងមកចាប់សក់នាយកន្ទាត់ ហើយលើកពេលក្បាលត្រូវរុញផ្ទប់ទៅលើពូក មហាវីនលួចចងអាឃាតក្នុងចិត្តទាំងទោមនស្ស៖

«អាចោលម្សៀតដេរីដ! ឯងទៅប្រាប់ពួកវាឲ្យមកសម្លាប់អញ ឬមួយក៏ឲ្យវាលេងល្ខោនលំៗ?»

ស្នូរចុចទ្វារសាជាថ្មី...

ពួកដៃដល់លែងក្បាលមហាវីនចេញពីការរកកលស្ទះថប់ដង្ហើមម្តងៗ ហាក់ប្រាប់មហាវីនថា ពួកគេពិតភ្ញាក់ផ្អើលនឹងស្នូរកណ្តឹងដែលរោទ៍នេះបំផុតហើយ។

មហាវីនខ្លួនឯងវិញដឹងខ្លួនដូចខ្មោចឲ៧ថ្ងៃ។ គេទើបតែយល់ថាអ្នកដែលនៅខាងក្រៅទើបសម ជាពួកដែលមកលេងល្បែង ចំណែកពួកនៅខាងក្នុងនេះប្រាកដជាឃាតករពិត។

ពេលនរកនៅនឹងមុខ ទើបបុរសនេះដឹងថា មួយជំហានពីសេចក្តីស្លាប់ និងការរស់រាន ត្រូវការ កម្លាំងចុងក្រោយមួយទើបអាចកំណត់បាន។ គេប្រមូលសេចក្តីក្លាហាន និងកម្លាំងកាយចិត្ត ហាក់ប្រាវទៅទង្គិចនឹងអំពូលចរណៃ លើកូនតុដែលអមដំណេក ធ្វើឲ្យសំឡេងទង្គិចលាន់ ឡើងស្រួយស្រឹប។

«បើកទ្វារ!»

អ្នកនៅខាងក្រៅស្រែកសន្ធាប់ធ្វើឲ្យមនុស្សទាំងបួននាក់ដកកាំភ្លើងចេញមកគ្រប់ដៃ។ សម្រាប់មហាវីន អារម្មណ៍ពេលនេះគឺការចូលពេទ្យបញ្ឆោតភ្នែក បានប្រែទៅជាទ្វារមរណ ភាពពិតប្រាកដមិនខាន.....ស្នូរកាំភ្លើងកើតឡើងលាយឡំគ្នា.....

វគ្គ អ្នកណាចង់សម្លាប់មហាវីន?

....នៅក្នុងច្រកអគារដ៏វែង នៃមន្ទីរពេទ្យ ចិត្រាដើរញាប់ជើងពីក្រោយ ស្នងការ Roy និង លោកឧត្តមសេនីយ៍ ឱត សាម៉ុន។ អ្វីដែលពួកគេនិយាយក្នុងពេលនេះជារឿងដែលខ្លួនត្រូវតែ ដឹងឮ មិនឲ្យខ្វះចន្លោះត្រង់ណា ព្រោះថាគ្រប់យ៉ាងនៃបទសន្ទនាពេលនេះប្រាកដជាពាក់ព័ន្ធ នឹងករណីលបធ្វើឃាតមហាវីន បុរសអ្នកមានដែលមានកម្មវិធីសមោសរដ៏ល្បីជាងគេមួយក្នុង ដៃ។

«ជនរងគ្រោះម៉េចហើយ!?»

លោកឱត សាម៉ុនសួរ ចំណែកអនាគតកូនប្រសាឆ្លើយយកគាប់គួរ៖

«ឆ្លងផុតហើយ តែនៅមិនទាន់ដឹងខ្លួនទេ!»

«ចុះរបាយការណ៍វេជ្ជសាស្ត្រ?»

Roy ឆ្លើយមិនបង្អង់គឺបានន័យថាគេពិតជាសូត្រវារត់មាត់មកបង្ហាញឪពុកក្មេក៖

«ត្រូវប្អូនគ្រាប់ចំស្មា ដៃខាងស្តាំ ពោះ នឹងបញ្ជិតថ្ពាល់ឆ្វេង!»

«អាយុវែងមែន!»

Roy ញញឹម ហើយឱនលំទោនសាជាថ្មីគោរពបុរសនេះរួចទើបវាចាតបវិញ៖

«ទេវតាមានភ្នែក!»

«ប្រហែលត្រូវការពេលយូរប៉ុនណា?»

«ពេទ្យថាតាមកម្លាំងអ្នកជំងឺ! អ្នកខ្លះត្រូវការពេល១២ម៉ោង អ្នកខ្លះអាចថាលើសពីនេះ!»

ពួកគេមកដល់បន្ទប់សង្គ្រោះបន្ទាន់ដែលមានប៉ូលិសពីរនាក់ឈរយាមកាម។ លោកឧត្តមសេនីយ៍សម្លឹងពួកគេហើយងាកមកបញ្ជាក់ជាមួយអនាគតកូនប្រសា៖

«កន្លែងនេះមានសុវត្ថិភាពទេសម្រាប់គេ?»

Roy ងាកភ្នែកសម្លឹងឆ្វេងស្តាំមុខក្រោយ ជាសញ្ញាសម្ងាត់របស់ប៉ូលិសដែលអាចដឹងដោយមិនបាច់និយាយថាអ្នកផ្សេងៗ វាយនៅជុំវិញនេះមិនមែនជាអ្នកជំងឺពិតទេ។ សូម្បីពេទ្យនិងគិលានុបដ្ឋាក ដែលអូសថ្នាំ ដើរទៅមក ធាតុពិតសុទ្ធតែជាកម្លាំងប៉ូលិសក្លែងបន្លំមករក្សាសុវត្ថិភាពមហាវីន។

«ស្រីម្នាក់នោះ?»

លោក ឱត សាម៉ុនសួរបន្ថែមឡើង ធ្វើឲ្យចិត្រាដកអារម្មណ៍ចេញពីទ្វារICUនិងប៉ូលិសបន្លំទាំងនោះ ហើយរេទៅរកមើលនាង។ នារីស្គមខ្ពស់ហើយមានសម្លៀកបំពាក់ថ្លៃកប់ កំពុងអង្គុយជ្រប់មុខក្បែរកាបូប Hummers តម្លៃស្មើរថយន្តមួយគ្រឿង។

«នាងឈ្មោះ Rose មេផ្នែកពិធីការ របស់អ្នករងគ្រោះ!»

ឱត សាម៉ុន សាជាថ្មីដៀងភ្នែកមើលជាតិ ចិត្រា។ ពួកគេទើបតែបានតម្រុយពីឯកមានថាស្ត្រីម្នាក់នេះ នៅពីក្រោយការអញ្ជើញភ្ញៀវទាំងអស់របស់សមោសរពណ៌ព្រះចន្ទ ពេលនេះនាងនៅពីមុខបន្ទប់ រង់ចាំដំណឹងចៅហ្វាយដូចកូនរង់ចាំម្តាយ។

ឧត្តមសេនីយ៍និយាយទៅកាន់ស្នងការបន្តទៀត៖

«អញ្ជើញនាងទៅបន្ទប់សួរនាំ! យើងប្រហែលមានអ្វីច្រើន ឲ្យនាងជួយសហការ!»

ចិត្រាឃើញនារីនោះងើបមុខមកដែរក្នុងពេលទន្ទឹមគ្នា ប៉ុន្តែឯកសណ្ឋានប៉ូលិសរបស់ពួកគេធ្វើឲ្យនាងក្រឡេកមួយឆាច់ប្រញាប់ងាកចេញវិញយ៉ាងរហ័ស។

«អាកប្បកិរិយានាងដូចជាចង់គេចប៉ូលិស ឬខ្លាចប៉ូលិស? ហេតុអ្វី? នាងគួរតែចង់ជួបប៉ូលិសដើម្បីជួយស្រាវជ្រាវរឿងពិតនៅពីក្រោយការរងគ្រោះរបស់ចៅហ្វាយទើបសម!»

គេដណ្ដឹងសួរខ្លួនឯងស្ងាត់ៗ ប៉ុន្តែធ្វើជាមិនដឹងខ្លួន និងមិនខ្វល់ពីប្រតិកម្មរបស់នាងអីបន្តិចណា។

«បងឈ្មោះ Rose?»

Roy ផ្ដើមសួរធ្វើឲ្យចិត្រាផ្ទង់ស្ដាប់ ទោះបីគេរក្សាអាកប្បកិរិយាដូចជាមិនខ្វល់ខ្វាយក៏ដោយ។

នារីពិធីការតបជាមួយសំឡេងនឹងនរបស់នាង៖

«ចាំ!»

Roy បន្តភ្លែត៖

«ខ្ញុំស្នងការ Roy! ខ្ញុំមានរឿងមួយចំនួនចង់ឲ្យបងជួយសហការ! ពេលនេះសុំអញ្ជើញបងទៅបន្ទប់សួរចម្លើយរបស់ប៉ូលិសក្នុងអគារនេះបានដែរទេ?»

«ចាសបាន!»

នារីនេះឆ្លើយតបខ្លីហើយនឹងន ពិបាកសន្និដ្ឋានបានថានាងកំពុងកើតទុក្ខពីរឿងអ្នកដែលនៅដេកស្មៀមខាងក្នុងពិតមែន ឬមួយនាងកំពុងមានវិបត្តិអ្វីផ្សេង។

«ខ្ញុំសូមដកហូតឧបករណ៍ទាំងអស់លើខ្លួនបង ហើយរក្សាទុកនៅខាងក្រៅ!»

«ខ្ញុំមិនមែនជាអ្នកទោសទេលោក!»

នាងស្រាប់តែមានប្រតិកម្មខឹងសម្បារយ៉ាងលឿនទាន់ហន់ ហើយចាប់ផ្ដើមបញ្ចេញភាពតឹងតែងលើសារសព្ទសំឡេង ពេល Royចង់សុំឃាត់ទុកសម្ភារៈទំនាក់ទំនងផ្ទាល់ខ្លួនទាំងអស់

របស់នាង។ ការប្រែប្រួលនេះ ធ្វើឲ្យគ្រប់គ្នាងាកមកសម្លឹង Rose ភ្លាមៗ រួមទាំងសក្តិបួនជាតិចិត្រាផង។

ផ្ទុយពីចរិតដែលប្រើជាមួយចិត្រាកន្លងមក ពេលនេះ Roy នៅតែធ្វើជាសុភាពបុរសហើយមិនខ្វីនឹងខឹងតបកាយវិការនាងទេ។ គេព្យាយាមពន្យល់៖

«នេះជាច្បាប់! សុំសហការផង!»

ស័ក្តិបួនអស់ពីចាប់អារម្មណ៍លើ Rose គេបែរជាផ្តោតមកតាមដានស្នងការ Roy ដែលមុនៗធ្លាប់តែនិយាយពាក្យក្រអឺតក្រអោងដាក់ ម្តេចក៏ពេលនេះចេះរក្សាឥរិយាបថសក្តិសម ជាប៉ូលិសសែនល្អបាន? មិនដឹងដោយសារថាទីនេះមានវត្តមានអនាគតឪពុកក្មេក ឬដោយសារអ្នកកំពុងដំឡើងសំឡេងដាក់គេនេះជាមនុស្សស្រីហើយស្អាតស៊ីវិល័យ?

«កែវភ្នែកស្នងការនេះ មិនដកចេញពីអាវវាលករបស់ស្រីស្អាតទេ! គេមានចរិតជាមនុស្សចូលចិត្តរឿងទាក់ទងស្រីៗប្រាកដណាស់!»

ឱត សាម៉ុនមិននិយាយអ្វីទេ ព្រោះគាត់បែរខ្នងមក ហើយភ្នែកទាំងគូផ្ចង់ផ្តោតទៅក្នុងបន្ទប់អ្នករបួស។ នៅទីនោះ ដំណក់ឈាមក្រហមក្រមៅដែលកំពុងហូរតក់ៗបញ្ចូលទៅឲ្យរាងកាយបុរសអ្នកមានដែលស្តូកមិនដឹងខ្លួន។

«បើបងFormat ទូរសព្ទចោលអស់អ៊ីចឹង! ប៉ូលិសរឹតតែអាចដាក់សំណួរផ្សេងៗបន្ថែមលើបងបាន!»

Roy និយាយធ្វើឲ្យចិត្រាបែរមកវិញ មើលនារីកាលីបខ្ពស់ ដែលកំពុងលើកទូរស័ព្ទទំនើបៗរបស់នាងមកលុបសម្អាតជាមួយម្រាមដៃស្ទាត់ជំនាញ។

ក្នុងពេលជាមួយគ្នា នាងហាក់មិនបានតក់ស្លុតថែមទាំងតបតមកវិញក្នុងសព្ទសំឡេងដែលលឿន ច្បាស់ ស្ទាត់ជាងម្រាមដៃរបស់នាងទៀត៖

«ខ្ញុំគ្រាន់តែការពារមិនឲ្យអ្នកណាម្នាក់អាចលួចទិន្នន័យផ្ទាល់ខ្លួនរបស់ខ្ញុំប៉ុណ្ណោះ លោកស្នងការ!»

ចិត្រាមិនអាចទប់ចិត្តដូចដែលឃើញស្នងការកំពុងប្រតិបត្តិចំពោះស្រីស្អាតសិចស៊ីឡើយ។ គេងាកមករកនាងចំៗហើយនិយាយៈ

«សុំទោស! បងទាក់ទងស្និទ្ធជាមួយមហាវីន! ជួនកាលទិន្នន័យខ្លះក្នុងទូរសព្ទ ដែលទុកស្នាមទំនាក់ទំនងរបស់អ្នកទាំងពីរ អាចជាភស្តុតាងសំខាន់អំណោយផលដល់ប៉ូលិសធ្វើការស៊ើបអង្កេត! បើពេលនេះបងនៅតែមិនព្រមឈប់បំផ្លាញទិន្នន័យ... ប៉ូលិសអាចដាក់បទចោទបានថាបងកំពុងបំផ្លាញភស្តុតាង បង្អាក់ការងារស៊ើបអង្កេត!»

គេដើរមកពីរបីជំហាន ហើយលូកមាត់និយាយបែបនេះជំនួស ព្រោះឃើញថា Roy កំពុងនៅស្ងៀមភ្លឹកនឹងសម្រស់បបូរមាត់ស្រីស្អាតក្រហមឈាមនោះបាត់ទៅហើយ។

ទោះយ៉ាងណា សម្តីចិត្រាធ្វើឲ្យ Rose ងើបមុខហើយងាកមកសម្លឹង។

របៀបដែលនាងសម្លឹងគឺឆ្មើងកន្ទ្រើងសំដៅសក្តិលើស្មាគេ បន្ទាប់មកនាងបោះបង់ការផ្តោតលើតួអង្គឋានៈតូចទាបរបស់យើង ហើយងាកទៅព្រមានអ្នកឋានៈធំៈ

«ស្នងការ Roy! លោកល្បីណាស់ សង្ឃឹមលោកធ្វើការបានល្អដូចឈ្មោះដែលល្បី! លោកឃើញហើយប៉ូលិសកូនចៅលោកកំពុងគំរាមខ្ញុំ! បើគេនៅតែមិនព្រមឈប់ទេ ខ្ញុំអាចនឹងដូរចិត្តលែងសហការផ្តល់ព័ត៌មានអីទាំងអស់ ហើយហៅមេធាវីខ្ញុំឲ្យមកជំនួសវិញ!!»

Roy ឱនមុខតែសម្លឹងទៅចិត្រាក្នុងកែវភ្នែកបន្ទោស។

ស័ក្តិបួនសង្កត់ចិត្តឈានថយក្រោយចាកចេញពីផ្លូវនារីដែលតម្កើងឫកស្មើមេឃម្នាក់នេះ បណ្តោយឲ្យ Roseពើងទ្រូង ធ្វើមុខឌឺ ហើយដើរកាត់ទៅមុខកូនប៉ូលិសយើង ទាំងវាហីមិនខ្ជីសូម្បីបែរមកសម្លឹងនាយ។

អារម្មណ៍ត្រូវគេមិនឲ្យតម្លៃ មិនមែនជារឿងថ្មីទេ ក្នុងសង្គមមួយដែលមនុស្សចូលចិត្តតែមើលលើសម្ភារៈ យសស័ក្តិនៅលើស្មា។

ចិត្រានៅស្ងៀមបានបន្តិច លោកឧត្តមសេនីយ៍ដើរមកក្បែរហើយដាក់ដៃមកលើស្មានាយគោះប៉ុកៗ ជាសញ្ញាផ្តល់កម្លាំងចិត្តឲ្យដូចរាល់ដង។

«គាត់ប្រហែលបានឃើញកិរិយាមិនសមជាស្នងការរបស់អនាគតកូនប្រសាម្នាក់នោះហើយ! សង្ឃឹមអ៊ីចឹងចុះ!»

នាយគិតម្នាក់ឯងក្នុងចិត្តតែមិនបាននិយាយអ្វីសូម្បីតែមួយម៉ាត់ណា។ លោក ឱត សាម៉ុន ឆ្លៀតផ្ដាំចិត្រាមុនពេលចេញទៅកាន់បន្ទប់ប៉ូលិសស្ដាប់ការសាកសួរៈ

«ចាំខ្ញុំនៅផ្ទះ ហើយតាមមើលអមរាជាមិនឲ្យឃ្លាតពីភ្នែក!»

តួនាទីខ្លួនគឺគ្មានសិទ្ធិអ្វីអាចនឹងចូលទៅស្ដាប់ការសាកសួរចម្លើយរបស់ប៉ូលិសស្រាប់ហើយ មិនសមឡើយថា មុននេះឆ្លោយប្រាណទប់ចិត្តមិនជាប់ ទៅហាបញ្ចេញយោបល់ ឲ្យនារីសិច ស៊ីស្ដីឲ្យលេងមកវិញបាននៅនឹងមុខស្នងការច្រឡើសបើសនោះទៀត?

ចិត្រាឱនគំនាប់ទាំងតូចចិត្តក្រោមកែវភ្នែកសម្លឹងស៊ីជម្រៅរបស់លោកឧត្ដមសេនីយ៍...

«ទុកចិត្តចុះទាន!»

គាត់ងក់ក្បាល! ហើយចាកចេញទៅ...

វគ្គ កំណត់ត្រាចម្លើយ

ដល់វេលាព្រះទិនករជ្រេទៅទិសខាងលិច ទើបគេឃើញរថយន្តឧត្ដមសេនីយ៍ ឱត សាម៉ុន លូនចូលមកដល់គេហដ្ឋានវិញ។

ចិត្រាក្រោកចេញទៅទទួលដល់ទ្វារ ព្រោះនាយដឹងថាចៅហ្វាយម្នាក់នេះហត់នឿយពេញមួយថ្ងៃជាមួយការសាកសួរក្រុមមនុស្សដែលជាប់ទាក់ទងជិតដិតនឹងជនរងគ្រោះមហារីន ហើយដែលប្រហែលជាមានច្រើនគ្នាផងបានជាដល់ថ្មើរណេះ។

«កូនអមរាជាមានចេញទៅណាអត់?»

នេះជាសំណួរមុនគេរបស់ឪពុកម្នាក់ដែលចោលបាយចោលទឹកពេញមួយថ្ងៃ ហើយក៏នៅតែមិនភ្លេចពីសុវត្ថិភាពកូនស្រីតែមួយគត់ជាចម្បង។

ចិត្រាកោតស្ញប់ស្ញែងទឹកចិត្តបុរសចំណាស់នេះដែលមានលើកូនស្រីក៏ដូចជាស្មារតីបំពេញការងារមិនចេះរារែកថមថយទៅតាមវ័យសោះនោះ។

«អ្នកនាងមិនចេញទៅណាទាំងអស់ទាន!»

គេឆ្លើយទាំងជួយទទួលយកកាបូបឯកសាររបស់គាត់។ លោក ឱត សាម៉ុន បោះជំហានចូលផ្ទះមួយៗទាំងធូរទ្រូងព្រោះដឹងថា ដោយសារការនិយាយគ្នាត្រង់ទៅត្រង់មកកាលម្សិលមិញបានធ្វើឲ្យអមរាជា យល់ការជាងមុន។

គាត់ងាកខ្សឹបរកចិត្រា៖

«ចូលបន្ទប់ធ្វើការខ្ញុំ! មានរឿងច្រើនត្រូវពិភាក្សាគ្នា!»

«បាយរៀបចំរួចហើយទាន!»

គេនិយាយកាត់ព្រោះបារម្ភពីក្រពះគាត់ តែបុរសជាមេកោយហាក់មិនបានខ្វល់ខ្វាយអ្វីក្រៅអំពីសំណុំរឿងដែលនៅចំពោះមុខនេះសោះ។ គាត់ក្រសោបស្មានាយហើយបណ្ដើរចូលបន្ទប់។ ផុតទ្វារកាលណា ឱត សាម៉ុន និយាយខ្សឹបខ្សៀវប្រាប់កូនប៉ូលិស៖

«ចិត្រា! លោកជឿអត់ថា ប៉ូលិសចាប់មិនបានជនល្មើសសូម្បីតែម្នាក់!»

គេនៅស្ងៀមប៉ុន្តែអារម្មណ៍ហោះហើរទៅរកបន្ទប់សណ្ឋាគារ ដែលមហាវីនត្រូវគេលបធ្វើឃាតហើយដែលកាសែតបានចុះផ្សាយព្រាតកាលពីព្រឹក។

«មិនសមថាគេចខ្លួនបានទាំងអស់ទេ!»

គេភ្លាត់មាត់តិចៗដូចបង្កឱកាសឲ្យលោកឧត្ដមសេនីយ៍និយាយបន្តពីក្រោយ៖

«តែវាជាការពិត »

ចិត្រានៅស្ងៀមធ្វើភ្នែកភ្លឹះៗពិចារណាការវិភាគបន្ទាន់ ដ៏គួរឲ្យភ្ញាក់ផ្អើលនេះ។ ទោះយ៉ាងណាគេមិនបានចូលរួមអង្កេតក្ដី មិនបានស្ដាប់ចម្លើយពីអ្នកដែលត្រូវប៉ូលិសសាកសួរមានតែនៅសំងំស្ងៀមចាំស្ដាប់ពីខាងបុរសនេះមកវិញ។

«ការសួរចម្លើយសន្តិសុខនៅទីកើតហេតុ គ្មានបានការអីទាំងអស់ ព្រោះទាំងបីនាក់សន្លប់ត្រូវថ្នាំ!»

«ដាក់ថ្នាំ? ចាំស្នុគដល់ម្លឹងដែរ?»

ឱត សាម៉ុនសើចសម្លឹងមុខនាយមុនពេលនិយាយបក៖

«វរសេនីយ៍ត្រី ចង់បានន័យថាឃាតករគួរសម្លាប់សន្តិសុខជាមុន?»

ចិត្រានៅស្ងៀម ពិចារណា។ តាមធម្មតា គេជាមនុស្សនិយាយច្រើន ឱ្យតែពេលដោះស្រាយក្តីគេចាប់ផ្តើមនិយាយស្តិតិចទៅៗ ហើយកាន់តែតិចពេលណាដែលគេមានអារម្មណ៍តឹងតែង។ប្រការនេះឧត្តមសេនីយ៍ឱត សាម៉ុនឃើញច្បាស់។

«កាមេរ៉ាខូចអស់! មុនពេលមានរឿង អស់សំណើចពេកហើយ!» គាត់និយាយបន្ថែម។

«មហាវីននិងអ្នកដែដល់អាចស្គាល់គ្នាពីមុនមកទេទាន?» គេសួរស្រាលៗហើយងើបមុខរង់ចាំចម្លើយពីគាត់។

លោក ឱត សាម៉ុនធ្វើមុខមាំមិនឆ្លើយ។

ពេលគាត់កំពុងចាក់ទឹក លាន់គ្រូកៗទៅក្នុងកែវនាយស័ក្តិបួនសួរបន្ថែម៖

«អ្នកណាជាអ្នកឃើញអ្នករងគ្រោះ?»

«លេខារបស់មហាវីនជាអ្នកប្តឹង!»

គាត់ឆ្លើយខ្លីហើយធ្មេចភ្នែកពិចារណាយ៉ាងស្មុគស្មាញ។

«ស្នាមរបួសទាំងបួនកន្លែងបញ្ជាក់ថា គេចង់សម្លាប់ចោលតែម្តង មិនមែនប្លន់ទេ!»

សម្តីគាត់ដែលកំពុងផ្តល់មកបន្ថែមនេះ ធ្វើឲ្យចិត្រារឹតតែនៅស្ងាត់ហើយពិចារណា។ មិនយូរប៉ុន្មានគាត់ថែមវ៉ាវមកទៀត៖

«Rose ម្នាក់ហ្នឹងជាពិធីការដែលទទួលខុសត្រូវរៀបចំសមោសរពណ៌ព្រះចន្ទឲ្យមហាវីនកាលពីពេលកន្លងមក! កំណត់ហេតុរាយការណ៍របស់នាយដែលនិយាយប្រាប់ប៉ូលិសកត់ត្រាមកថា ប៉ុន្មានម៉ោងមុនកើតហេតុ អ្នករងគ្រោះទៅរកនាងដល់ផ្ទះ ហើយផ្តាំឲ្យនាងដំណើរការក្រុមហ៊ុនជំនួសបណ្តោះអាសន្ន! នាងថាមហាវីនខ្លួនឯងដូចជាដឹងខ្លួន ថាជិតមានគ្រោះថ្នាក់ហើយថា គេចង់ចាកចេញទៅកូរ៉េតែទិញសំបុត្រមិនបាន! ប៉ុន្តែ លេខាគេឈ្មោះដេវីដ ដែលយើងសួរនៅឯស្នងការ ផ្តល់ចម្លើយមកខុសគ្នា! ម្នាក់នោះនិយាយថា Rose មិនពិត ហើយបញ្ជាក់ថាមហាវីនមិនបាននិយាយអ្វីនឹងRoseទេគ្រាន់តែទៅនិយាយពីរឿងបិទសមោរសរប

ណ្ដោះអាសន្ន ហើយគេនិយាយចប់សប្បាយចិត្តណាស់ក៏ចេញទៅរាំលេង មុនពេលស្រវឹងវិលមកដេកផ្ទះ។»

ចិត្រាផ្ទុះសំណួរព្រោះចូលដល់ចំណុចកំពូលប្រស្នា៖

«ដេវីដដូចជាចង់ឱ្យRose ទាក់ទងជាមួយការធ្វើឃាតនេះ!»

ឧត្តមសេនីយ៍ងក់ក្បាលហើយឆ្លើយ៖

«តែខ្ញុំគិតថាអាម្នាក់ហ្នឹងហើយដែលមានបញ្ហាជាងគេ!»

«រវាងជំនួយការនិងពិធីការនោះ ធ្លាប់មានអ្វីឃ្មើសគ្នា?»

ឱត សាម៉ុនបោះក្រដាសមកមួយសំណុំ៖

«របាយការណ៍ប៉ូលិសយើងដែលបានស្ទាក់សួរចម្លើយអ្នកពាក់ព័ន្ធនិងអ្នករងគ្រោះ! ទាំងនៅផ្ទះ  និងក្រុមហ៊ុននានារបស់មហាវីន! បុគ្គលិកដែលស្និទ្ធនិងបីនាក់នេះ អះអាងថានាងRose និងដេវីដមិនដែលមានប្រវត្តិត្រូវគ្នាទេ! ពួកគេតែងតែប្រជែងគ្នាឥតល្ហែ! ខ្ញុំកំពុងឱ្យស្នងការRoyបន្ថែមការប្រុងប្រយ័ត្នចំពោះពីរនាក់នេះ»

ចិត្រាងក់ក្បាលផ្ងក់ៗហើយនិយាយ៖

«វាទំនងណាស់ដែលថា អ្នកដៃដល់ ជាអ្នកណាម្នាក់ក្នុងចំណោមពីរនាក់ក្បែរខ្លួនគេនេះ!ខ្ញុំនិយាយសំអាងលើហេតុផលពីរ ពួកគេជាអ្នកនៅជាមួយជនរងគ្រោះក្រោយគេហើយចម្លើយពួកគេមានសភាពមិនត្រូវគ្នា! ប្រសិនស្នងការRoyរកឃើញអ្នកណាម្នាក់ជាអ្នកកុហកក្នុងចំណោមពីរនាក់នេះ យើងកាន់តែមានពន្លឺច្រើន»

ឱត សាម៉ុនបង្ហាញអាការៈផ្ចិតផ្ចង់ទៅលើការត្រិះរិះហើយស្រដី៖

«អ្នករងគ្រោះនៅដេកនៅឡើយ តែយើងគិតដល់រឿងច្រើន! អាចថាមហាវីនរកបានតម្រុយអ្វីម្យ៉ាងបកអាក្រាតពួកគេ បានជាគេចាំបាច់ត្រូវសម្លាប់?»

«ហើយបើសិនជា អ្នកសម្លាប់គេមានទាក់ទងរឿងបាត់ខ្លួនស្រីៗកូនអ្នកមានទៀត វារឹតតែទំនង ណាស់ ព្រោះថា អ្នកនោះអាចជាអ្នកដែលដឹងពីសមោសររបស់មហាវីនច្បាស់ ទើបអាចប្រើប្រាស់កម្មវិធីរបស់គេទៅធ្វើរឿងឧក្រិដ្ឋផ្សេងបាន!»

«លោកថាអ្នកណាក្នុងចំណោមពីរនាក់នោះជាតិ ចិត្រា?»

លោក ឱត សាម៉ុន បង្វិលចម្លើយឲ្យក្លាយមកជាសំណួរវិញ ហើយហៅឈ្មោះនាយទាំងត្រកូលទៀត។ ចិត្តថ្លើមនាយសក្តិប្អូនកាន់តែចូលស៊ុបជាមួយបទវិភាគ សួរបកវិញ៖

«ចុះ ពិធីការស្រីម្នាក់នោះនិងលេខាដេវីដ គេបានសារភាពដែរទេ ថាធ្លាប់ឮមហាវីន និយាយថាសង្ស័យអ្នកណារឿងបាត់ខ្លួនស្រីៗ៥នាក់?»

ឱត សាម៉ុនគ្រវីក្បាល ជាសញ្ញាបដិសេធ៖

«សួរហើយ តែពួកគេមិននិយាយ! បើផ្អែកតាមការរកឃើញរបស់ឯកមាន មហាវីននេះ មុនពេលធ្លាក់ខ្លួនរងគ្រោះ គេក៏ធ្លាប់ទាក់ទងជួលHacker លើផ្សារងងឹតឲ្យតាមដានបណ្តាញរបស់តារាសប្បុរស Lorenzo ម្នាក់នោះ យើងអាចហៅគេមកសួរបានគ្រប់ពេល! ប៉ុន្តែខ្ញុំចង់ឲ្យលោកពិនិត្យចម្លើយរបស់ម្នាក់នេះសិន!»

គាត់បើកទូរសព្ទបង្ហាញរូបភាពវីដេអូលេខាឈ្មោះដេវីដ ដែលត្រូវបានថតទុកក្នុងពេលប៉ូលិសធ្វើការសាកសួរ…

«ថៅកែវីននៅម្នាក់ឯង! ខ្ញុំត្រឡប់ទៅផ្ទះ ម៉ោងមួយយប់ហើយ! ប៉ុន្តែមិនដឹងម៉េច ខ្ញុំស្រាប់តែមានអារម្មណ៍ថា មិនស្រួល ចិត្តគ្មានមូលហេតុសោះ ក៏នៅសុខៗ ខលទៅគាត់! អត់មានអ្នកលើក ! ខ្ញុំចង់ឱ្យសន្តិសុខបើកវីដេអូមើលសកម្មភាពជុំវិញផ្ទះ ខលទៅគ្មានសន្តិសុខណាលើក ខ្ញុំក៏បកឡានមករកគាត់វិញថាមកគេងជាមួយគាត់! តាមផ្លូវ ខ្ញុំខលទៅហៅគ្នាខ្ញុំខ្លះមកជាមួយ! ពេលមកដល់គឺមានគេកំពុងនៅក្នុងហើយធ្វើបាបគាត់!»

ចិត្រាធ្វើភ្នែកមមីព្រោះសម្តីលេខានេះ មើលទៅមានចំណុចមិនច្បាស់លាស់ច្រើន។នាយរអ៊ូម្នាក់ឯង៖

«ជួនល្អពេកហើយ! !»

«លោកមិនយល់ស្របពាក្យចម្លើយគេត្រង់ណាខ្លះ?»

ចិត្រាឆ្លើយភ្លាមមិនបង្អង់៖

«អត់សូវសមត្រង់សម្តីគេនិយាយថា មានអារម្មណ៍មិនស្រួលចិត្តដោយគ្មានមូលហេតុ! បន្ទាប់មក គេបកឡានមកវិញ! មួយទៀតនៅតាមផ្លូវក៏នឹកឃើញខលទៅហៅគ្នាគេខ្លះឱ្យមកជាមួយ! ពេលមកដល់ចំពេលអ្នករងគ្រោះកំពុងត្រូវគេ ធ្វើបាបទៀត?»

«វាមិនទំនងត្រង់ណាខ្លះ? ចំណុចណាខ្លះលោកសង្ស័យ?»

នាយសក្តិបួនគ្រវីក្បាលតិចៗ ហើយពន្យល់បុរសនេះ៖

«ដំបូងក្រែងគេប្រកែកសម្តីរបស់ Roseហើយអះអាងថា មហារីនសប្បាយចិត្ត ចុះក្រោយមកម៉េចក៏គេបែរជាមិនស្រួលចិត្តហើយគិតថាចៅហ្វាយអាចនឹងមានរឿងមិនស្រួលបកឡានទៅវិញ? ពាក្យចម្លើយទាំងពីកថាខណ្ឌនេះមិនស៊ីសង្វាក់គ្នាតែម្តងទាន!»

លោកឱត សាម៉ុន គាត់ងក់ក្បាលញញឹម។

«អ្នកសួរចម្លើយពួកគេសមណាស់ តែជាលោកជាតិ ចិត្រា!»

គេមិនតបព្រោះមិនចង់បន្ថែមការវាយតម្លៃថា អ្នកសួរចម្លើយមុនៗដែលសរសេររបាយការណ៍មកនេះ នៅខ្សោយការចងចាំលើបណ្តាចំណុចសំខាន់ៗ ក៏ដូចជាភាពមិនស៊ីមេទ្រី គ្នាក្នុងអង្គចម្លើយរបស់សាក្សី ។

តែឧត្តមសេនីយ៍នៅតែវាចាមកបន្ថែម៖

«មានតែពីរទេ មួយគេជាអ្នកធ្វើហើយរត់មកប្តឹង ពីរ គេកំពុងចង់ឱ្យប៉ូលិសទម្លាក់ការសង្ស័យទៅលើសត្រូវគេ!»

«Rose?»

ចិត្រាងើបមុខសួរខ្លីតែនៅដំអក់រង់ចាំស្តាប់ការវាយតម្លៃរបស់បុរសចំណាស់ដ៏មានបទពិសោធន៍។ ឃើញដូច្នេះ ឧត្តមសេនីយ៍និយាយបកស្រាយ៖

«លេខាដេវីដ អាចនឹងធ្វើទង្វើពីរខាងលើដោយសារហេតុផលពីរផ្សេងទៀត! ទីមួយគឺ គេជាដឹងថា Roseបានក្បត់មហារីនឯមួយទៀតខ្លួនគេក្បត់មហារីន!»

«ដើម្បីអ្វីទៅ ក្នុងការក្បត់មហារីន?»

ឱត សាម៉ុនលើកដៃរាកាត់ព្រោះទូរសព្ទលោកញ័ររង្គើរិលខ្វាល់....

គាត់ឈ្ងោកចុចអានសារហើយងើបមុខមកវិញយ៉ាងរហ័ស៖

«មហាវីនដឹងខ្លួនហើយ!»

ភាគទី១៧

សាជាថ្មីអ្នកទាំងពីរបានទៅដល់មន្ទីរពេទ្យទាំងមេឃងងឹត...លោកឱត សាម៉ុនមកដល់មាត់ទ្វារបន្ទប់មើលពីក្រៅទៅក៏ឃើញមហាវីនមុខហើមពោរ អង្គុយសញ្ជប់សញ្ជឹង លើគ្រែរីស័រទាំងដៃជាប់សេរ៉ូម។

នៅខាងក្រៅកញ្ចក់ លេខាឈ្មោះដេវីដអង្គុយសំកុកសម្លឹងមកម្ចាស់ ធ្វើឲ្យឧត្តមសេនីយ៍ ឱត សាម៉ុនចេញបញ្ជា៖

«មិនឱ្យអ្នកណានៅក្បែរ បន្ទប់នេះ!»

ដេវីដងើបមុខមកសម្លឹងឧត្តមសេនីយ៍ ។

ឱត សាម៉ុនធ្វើហីហាក់មិនដឹងខ្លួន ហើយចេញបញ្ជាបន្ថែមទៅរកអ្នកយាមទ្វារទាំងពីរ៖

«ចូលទៅក្នុង ទាញវាំងននបិទឱ្យជិតមិនឱ្យអ្នកក្រៅណាអាច មើលឃើញសកម្មភាពខាងក្នុងបន្ទប់ជនរងគ្រោះដាច់ខាត!»

Roy ក្រពាត់ដៃសម្លឹងចិត្រា។ ចិត្រាច្បាស់ក្នុងចិត្តណាស់ថាស្នងការម្នាក់នេះ មិនចង់ឲ្យខ្លួនចូលរួមស្តាប់ការណ៍នៅទីនេះទេ ទើបគេរំសៀកខ្លួនបម្រុងចាកចេញតែត្រូវលោកឱត សាម៉ុនឃាត់។

«ជាតិ ចិត្រាចូលជាមួយខ្ញុំ!»

នាយ Roy មិនសប្បាយចិត្តប៉ុន្មានឡើយ ចំពោះការសម្រេចចិត្តនេះ គ្រាន់តែគេមិនហ៊ានថាអ្វី។

មកដល់បន្ទប់ភ្លាម គាត់សួរភ្លែត៖

«លោកដឹងមែនទេ! អ្នកណានៅពីក្រោយរឿងធ្វើឃាតនេះ?»

មហាវីន នៅរក្សាភាពស្ងប់ស្ងៀមទឹកមុខនឹងនខកចិត្ត។

បុរសអ្នកមានដែលកំពុងបាក់ស្លាបមិនទាំងព្រម សូម្បីតែដៀងភ្នែកសម្លឹងវត្តមានប៉ូលិសទាំងបី។

ឧត្តមសេនីយ៍ព្រហ្មទណ្ឌយល់ច្បាស់ពីស្ថានភាពរបស់មហាវីន ដែលកំពុងខ្វល់ចិត្តឥតគណនានឹងវាសនាបត់បែនស្មានមិនដល់របស់ខ្លួនក្នុងពេលនេះ ។

ប៉ុន្តែគាត់ត្រូវធ្វើពើសិនព្រោះគេដឹងថាមុននឹងក្រោយប៉ូលិសគង់តែឈ្លេចសួរទាល់តែបានចម្លើយ។ បុរសចំណាស់ឃើញចិត្រាអោនកត់ត្រា។ គាត់ចង់ឱ្យគេចូលរួមជាមួយក្នុងការអង្កេតស្ថានភាពមហាវីននិងឥរិយាបថរបស់គេ។

«លេខាលោក ជាអ្នកទៅទាន់ហេតុការណ៍! គេនិយាយថា គេមានសេចក្ដីសង្ស័យបានបើកឡានបកទៅវិញ!តែចម្លើយគេមានកន្លែងមិនស៊ីសង្វាក់គ្នាច្រើន! លោកយល់ម៉េចដែរ បើប៉ូលិសដាក់ការសង្ស័យដល់ជននោះ?»

មហាវីនស្ងប់ស្ងាត់តែគ្រប់ភ្នែកគេពុះកញ្ច្រោល។

«ប៉ូលិសស្រាវជ្រាវឲ្យរហ័សទៅអ៊ីចឹង!»

គេនិយាយហឺៗហើយខ្លីៗ។

មនុស្សប្រភេទគេនេះ មេប៉ូលិសដូចលោកឱត សាម៉ុន ជួបសឹងថាធ្លាប់ទៅហើយ។

គាត់អោនមកអង្គុយទល់មុខគេ មិនឱ្យគេចបានតែម្ដងហើយថែមទាំងសម្លឹងមហាវីនធ្វើឲ្យបុរសនេះនៅមិនសុខជាមួយកែវភ្នែកស៊ីជម្រៅរបស់ឧត្តមសេនីយ៍។

គេដឹងថា មេព្រហ្មទណ្ឌម្នាក់នេះមិនមែនងាយស្រួលឲ្យគេបង្វិលបានដូចការស្មានដំបូងឡើយ។ ម្ល៉ោះហើយ បុរសធាត់ចាប់ផ្ដើមកែពាក្យ៖

«បើខ្ញុំចេះតែផ្ដល់ចម្លើយតាមចិត្តនឹកឃើញដល់ប៉ូលិស អ្នកនោះអាចប្ដឹងខ្ញុំបកវិញ អ្នកណាដឹងថា ប៉ូលិសអាចមានលទ្ធភាពរកភស្តុតាងប្រឆាំងគេឃើញដែរអត់? គឺវាគ្មានន័យ!»

ឱត សាម៉ុនដឹងខ្លួនកំពុងត្រូវគេឌឺគាត់នៅតែតបតក្នុងសំឡេងសុភាពនឹងនៈ

«អ្នករងគ្រោះមិនសហការ ឲ្យប៉ូលិសទៅរកតម្រុយពីណាមក កុំថាឡើងដល់ទៅភស្តុតាង!»

មហាវីននៅស្ងៀម Roy ចាប់ផ្ដើមលូកមាត់៖

«បួនគ្រាប់ដែលគេឲ្យលោក គឺគេមិនចង់ឲ្យលោករស់ទេ! លាក់ខ្លួននៅទីនេះក៏មិនមែនរឿងគ្រប់គ្នាចង់ធ្វើដែរ តែបើយើងរកមនុស្សអស់នោះនឹងអ្នកនៅពីក្រោយមិនបាន លោកនឹងគ្មានសុវត្ថិភាពជារៀងរហូត!»

គេធ្វើមុខដូចចង់យំហើយស្មុគស្មាញចិត្តច្បាស់ក្រឡែត។ ពីដំបូងគិតថាខ្លួនឯងឆ្លាត

ចុងក្រោយ ពេលមច្ចុរាជបង្ហាញខ្លួន គេចាប់ផ្ដើមវិលក្បុង។

គេនិយាយព្រោះគេមិនអាចនៅស្ងៀមនៅចំពោះសំណួរមេប៉ូលិសអស់នេះបាន៖

«មានមនុស្សម្នាក់ ខ្ញុំមិនដឹងប្រភពគេ តែគេបានមកទាក់ទងកូនចៅខ្ញុំ! ពួកគេរាប់អានគ្នា ខ្ញុំក៏មិនថាអីព្រោះខ្ញុំយល់ថា មនុស្សត្រូវការប្រយោជន៍ពីគ្នាទៅវិញទៅមក! ក្រោយមកគេក្លាយជា Sponsor ធំរបស់សមោសរពណ៌ព្រះចន្ទ! មនុស្សគ្រប់គ្នាចូលរួមកម្មវិធីនេះ សុទ្ធតែស្ញប់ស្ញែងភាពមានបានរបស់គេ ហើយចង់ជួបគេ! ក្រោយមកប៉ូលិសប្រកាសថាភ្ញៀវ៤នាក់របស់ខ្ញុំបានបាត់ខ្លួន! ខ្ញុំចាប់ផ្ដើមមិនសប្បាយចិត្ត! ខ្ញុំដឹងថាកូនចៅខ្ញុំ Rose បានជួយរៀបការណាត់ជួបពិសេស រវាងស្រីៗអស់នោះនឹងអាម្នាក់នោះ ខ្ញុំក៏ហៅនាងមកសួរហើយប្រាប់នាងថា ខ្ញុំសង្ស័យវា! ក្រោយមកមិនដឹងនាងនិយាយនឹងវាបែបណា ខ្ញុំក៏មានអារម្មណ៍គ្រោះថ្នាក់កាន់តែចូលមកកៀក! ឡានខ្ញុំត្រូវគេផ្ដាច់ហ្វ្រាំង ហើយចុងក្រោយខ្ញុំសម្រេចចិត្តថា ផ្អាកសមោសរនោះសិន!»

Roy សម្លឹងឱិត សាម៉ុន។ បុរសចំណាស់នៅឈ្ងោកគិតមិនចេញស្ដី ទុកឲ្យ Roy លាន់មាត់សួរ៖

«Lorenzo?»

មហាវីនហាក់បង្ហាញភាពកំសាក គេនិយាយរញ៉ីរញ៉ៃ៖

«ឈប់! ខ្ញុំមិនទាន់បានចោទគេទេ ព្រោះខ្ញុំគ្មានភស្តុតាងគ្មានសាក្សី!!»

«ចុះហេតុអី មិនព្រមប្ដឹងប៉ូលិស?»

ឱត សាម៉ុនសួរដោយសម្លឹងភ្នែកគេ។

«ប្រាប់ហើយថាខ្ញុំគ្មានស្អីសំអាងសម្រាប់ប្ដឹងគេទាំងអស់!»

ដោយទើសចិត្តនឹងការបន្លាយពេលគ្មានប្រយោជន៍នេះ ចិត្រានិយាយផ្ទួង៖

«មិនមែនទេ! ការពិតលោកឯងភ័យខ្លួនដែលចូលទៅលុកលុយបណ្ដាញរបស់គេហើយត្រូវគេតាមទាន់ចាប់ថ្នាក់បាន!»

ទោះបីលើកនេះ មហាវីនធ្វើដូចអ្នកមុនៗ គឺសម្លឹងសក្តិលើស្មានាយចិត្រា។ ចិត្រាតាំងចិត្តនិយាយបន្តឲ្យចប់ចុងចប់ដើម៖

«លោកជួល Hackerថៃ ចូលទៅកកូរបណ្ដាញផ្ទាល់ខ្លួនរបស់អាណិកជននោះ លុះដឹងថាគេក៏ខ្លាំងមិនធម្មតា លោកចាប់ផ្ដើមរត់គេច!»

មហាវីន និង Roy សុទ្ធតែស្មានមិនដល់ទេថា រឿង Hacker ដ៏ស្ងាត់កំបាំងនៅមិននៅ ត្រូវបានលាតត្រដាងចេញមកដោយប៉ូលិសស័ក្តិបួនម្នាក់។

ទោះបីជាយ៉ាងណា មហាវីនវិញ ក៏មិនខ្វះសម្ដីការពារខ្លួនដូចគ្នា៖

«ខ្ញុំសង្ស័យគេ បានជាចំណាយពេលតាមដានគេនិងប្រើ Hacker ម្នាក់នោះ!»

ឱត សាម៉ុនគ្រហែមយកសំឡេង មុនពេលប្រាប់ទៅមហាវីន៖

«លុកលុយចូលបណ្ដាញឯកជនរបស់អ្នកដទៃជាអំពើខុសច្បាប់! លោកចង់ស្ដាប់ចង់ដឹងរឿងរ៉ាវរកស៊ីរបស់គេប្រាក់លាន បើគេប្ដឹងបក លោកនឹងគ្មានលុយសងទេ!»

មហាវីនមិនខ្វះពាក្យតវ៉ា៖

«ព្រោះខ្ញុំទ័ល! សកម្មភាពមនុស្សម្នាក់នោះធ្វើឲ្យប៉ះពាល់ដល់អាជីវកម្មខ្ញុំ ហើយខ្ញុំក៏មិនដឹងដែរថាគេនិង Rose កំពុងធ្វើអ្វីនៅពីក្រោយខ្នងខ្ញុំ?»

«លោកយល់ថាអ្នកណាជាអ្នកដាក់មនុស្សទៅសម្លាប់លោកក្នុងផ្ទះលំហែ? ហើយគេធ្វើម៉េចដឹងថាលោកទៅទីនោះ?»

Roy សួរដោយសម្លឹងមហាវីនពីលើដល់ក្រោម។ បុរសធាត់ដកដង្ហើមធំ ហើយនិយាយ៖

«មានតែពីរនាក់គត់ដែលខ្ញុំជួបកាលពីយប់ម្សិលហើយដឹងពីស្ថានភាពរបស់ខ្ញុំ! ម្នាក់គឺ Rose ម្នាក់ទៀតគឺដេវីដ! ចំណែកឲ្យខ្ញុំសង្ស័យដេវីដ គឺខុសទាំងស្រុង ព្រោះបើគេចង់សម្លាប់ខ្ញុំមែន គេមិនបាច់ប្ដឹងប៉ូលិសឲ្យឡើងមកជួយខ្ញុំទេ!»

និយាយទៅនិយាយមក ម្នាក់នេះដូចជាចង់បង្ហាញប៉ូលិសថា គេដាក់ការសង្ស័យទៅលើ នារីឈ្មោះ Rose ដែលមានអាកប្បកិរិយាដ៏ខែងរ៉ែងកាលពីព្រឹក។

ស្នូរទូរសព្ទលោតពីក្នុងដៃលោកឧត្តមសេនីយ៍។ គាត់ដើរចេញពីបន្ទប់ដើម្បីនិយាយ។

ចិត្រាដឹងថាបើពុំមែនអមរាដា គាត់មិនរលះរលាំងលើកទេ។ ទោះបីយ៉ាងណាមហាវីន កាន់តែមានភាពតក់ក្រហល់ខ្វល់ខ្វាយថែមឡើង....

«ហេតុអ្វីលោកមើលទៅដូចជាមិនសូវទុកចិត្តRoseអ្ហះមហាវីន? ហើយល្ងាចមិញ មុនមានរឿងលោកទៅផ្ទះគេនិយាយរឿងអ្វីខ្លះ?

»Royសួរដើម្បីផ្ទួរផ្ទងចម្លើយគេ។ ឱ្យតែគេឆ្លើយមកខុសគ្នាពីអ្វីដែលRoseឬដេវីដបាននិយាយ គេអាចធ្វើការសន្និដ្ឋានដឹងបានហើយថា អ្នកណាជាអ្នកកុហកក្នុងចំណោមពួកគេ។

គេនោះរិះគិតចុះឡើង  រិះគិតយ៉ាងណាក៏មិនដាច់ចិត្តឆ្លើយសោះ។ គេបណ្ដោយឱ្យប៉ូលិសទាំងពីររង់ចាំអស់មួយខណៈទើបRoyចាប់ផ្ដើមនិយាយ៖

«លោកចង់វែកមុខឃាតករដែរអត់មហាវីន!?»

«ខ្ញុំហត់ណាស់! ខ្ញុំវិលមុខ ខ្ញុំចង់ជួបពេទ្យ! ខ្ញុំចង់សម្រាក!»

មហាវីនចេញក្រឡាគេចវេះ។

ប៉ូលិសទាំងពីរមើលមុខគ្នា..... ហើយRoyធ្វើមុខស្មើហាក់ខឹង។

គេក្រោកដើរចេញលែងមាត់ ប៉ុន្តែមកដល់មាត់ទ្វារគេបញ្ជាពួកអ្នកយាម៖

«អត់ឱ្យអ្នកជំងឺខាងក្នុងជួបអ្នកណាទាំងអស់ក្រៅពីពេទ្យ! អត់ឱ្យនិយាយទូរស័ព្ទ អត់ឱ្យមានអ្នកសួរសុខទុក្ខ !»

ចិត្រាដើរចេញមកតាមពីក្រោយ ព្រោះពេលនេះមហាវីនបិទភ្នែកហាក់បដិសេធមិនចង់និយាយនឹងប៉ូលិសណាទៅហើយ។

នាយសក្តិបួនដឹងច្បាស់ថា Royកំពុងចង់ជាន់កែងមហាវីន ក្នុងការមិនអនុញ្ញាតឱ្យគេមានឱកាសជួបនិយាយជាមួយអ្នកណាសូម្បីតែRoseរីដេវីដ វាជាវិធានការណ៍បង្ការមិនឱ្យអ្នកមានដ៏ក្រឡេចក្រឡុចនេះអាចមានឱកាសជួយធ្វើឱ្យភាគីណាមួយមានពាក្យចម្លើយ ស៊ីសង្វាក់គ្នានឹងសម្តីរបស់គេខ្លួនឯង។

ពេលណាដែលប៉ូលិសបង្ខំបានចម្លើយពីមាត់គេ ប៉ូលិសអាចដឹងបានថាក្នុងចំណោមមនុស្សបីបាក់គឺថៅហ្វាយ លេខានិងមេពិធីការមានពាក្យចម្លើយខុសគ្នាដល់កម្រិតណាមិនខាន។

វគ្គ ក្បាច់បង្វែងដាន

នៅអគារក្រោមបង្អស់របស់មន្ទីរពេទ្យដែលស្ងាត់ច្រៀបព្រោះរាត្រីកាល លោកឧត្តមសេនីយ៍ឱត សាម៉ុន ដើរលឿនស្លេវមកប៉ូលិសទាំងទ្វេដែលពួកគេទើបនឹងចុះមក។

គាត់ទាញពួកគេចូលទៅក្នុងឡាន ប្រាកដថាគ្មានអ្នកទីបួនអាចឮបានហើយទើបផ្តើមលើកទូរសព្ទមកចុចសំឡេងមួយឱ្យម្នាក់ៗស្តាប់ឮ....

«សូមជម្រាបពូ! ផានូស្រាប់តែភ្លាមៗនេះទទួលបានសារឱ្យទៅចូលរួមកម្មវិធីជាថ្មី គេថា គេសម្រេចចិត្តទៅ សមោសរព្រះចន្ទម៉ោង៩យប់នេះ!គេទៅជាមួយអង្គរក្សរបស់គេហើយឱ្យខ្ញុំបន្លំធ្វើតែកុង!»

គ្រប់គ្នាឮ ហើយបើកភ្នែកធំៗជាងគេគឺចិត្រា គេសួរទៅបុរសចំណាស់ភ្លាម៖

«ក្រែងលេខាមហាវីនថាកម្មវិធីនោះបិទ? »

Royងើបមុខសម្លឹងនាឡិកាឡាន ទ្រនិចបង្ហាញថាម៉ោង៧យប់ហើយ។ មាត់គេនិយាយបណ្តើរ៖

«ខ្ញុំសួរបញ្ជាក់ទៅRose!»

លោកឱត សាម៉ុន ឆ្លើយ៖

«ម្នាក់ហ្នឹងខ្ញុំចង់ឃាត់មកសួរនាំរឿងសំខាន់មួយចំនួនធំទៀត! បើលើកនេះមហាវីនពិតជាបានបិទសមោសរហើយនាងថ្លើមធំហ៊ានកោះហៅភ្ញៀវយើងកាន់តែមានហេតុផលក្នុងការឃាត់ខ្លួនមកសួរនាំ!»

Royមើលមកលោក ឱត សាម៉ុន ហើយគ្រវីក្បាលជាសញ្ញាថាគេមិនស្របថាជា Rose ។ គេលើកSMSបង្ហាញមកវិញថាក្នុងពេលជជែកគ្នានេះ នាងឆ្លើយមកវិញហើយថាគ្មានពាក់ព័ន្ធអ្វីនឹងការអញ្ជើញថ្មីនេះទេ។

«ខ្ញុំឆាតទៅសួរ គេតមកភ្លាម បានន័យថាRose ក៏មិនដឹងពីការអញ្ជើញថ្មីឲ្យទៅសមោសរនោះដែរ បានន័យថាមានអ្នកទីបីណាម្នាក់ទៀត កំពុងចង់ទាញយកផានូ និងអ្នកឯទៀតចូលអន្ទាក់វា?»

Roy និយាយទាំងញ័រមាត់។

លោកឧត្តមសេនីយ៍អានសារឱ្យប្រាកដហើយនិយាយតបទៅស្នងការក្មេង៖

«ធ្វើការលឿនគ្រាន់បើ! អូខេ ឥឡូវនេះ ជួយពូរឿងមួយRoy!»

«មានប្រសាសន៍មកចុះ!»

«ពូបញ្ជូនមនុស្សឲ្យទៅជាមួយផានូ! គឺទៅយប់នេះ!»